**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## កិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល លេខ ១២/២០០៤ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុមការងារពិសេសអន្តរក្រសួងស្តីពីកិច្ចសម្របសម្រួលពាណិជ្ជកម្មនិងបរិយាកាសវិនិយោគ
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល លេខ ៤៤ សសរ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល លេខ ៤៦ សសរ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតអនុគណៈកម្មការដើម្បីដឹកនាំការងារអភិវឌ្ឍន៍ផ្នែកឯកជន
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៣២សសរ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីកំណែតំរូវឈ្មោះគណៈកម្មការដឹកនាំការងារអភិវឌ្ឍន៍ផ្នែកឯកជន និងការបន្ថែមសមាសភាពសមាជិកនៃអនុគណៈកម្មាធិការសហគ្រាសធុនតូច និងមធ្យម



ឃ

- យោងសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលលេខ ៩០ សជណ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥

- យោងស្មារតីនៃអង្គប្រជុំបើកទូលាយរបស់គណៈកម្មាធិការដឹកនាំដើម្បីអភិវឌ្ឍន៍ផ្នែកឯកជននាថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពី យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ

- តាមតំរូវការចាំបាច់នៃការងារ ។

# សម្រេច

## ជំពូកទី ១

## ក្រុមសម្របសម្រួលអន្តរស្ថាប័ន

**មាត្រា ១.-**

ក្រុមសម្របសម្រួលអន្តរស្ថាប័នមួយត្រូវបានបង្កើតឡើង ដើម្បីបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងប្រតិបត្តិការនៃការនាំចេញ នាំចូលទំនិញ តាមរយៈការអនុវត្តន៍ការគ្រប់គ្រងហានិភ័យ ។ ក្រុមសម្របសម្រួលអន្តរស្ថាប័ននេះ មានភារៈកិច្ចដូចខាងក្រោមៈ

១. ធានាសម្រេចឱ្យបាននូវតុល្យភាពផ្អែកលើហានិភ័យប្រកបដោយប្រសិទ្ធិភាព រវាងអន្តរាគមន៍ខាងបទប្បញ្ញត្តិ និងការសម្រួលពាណិជ្ជកម្ម ក្នុងចំណោមក្រសួង និងស្ថាប័នដែលពាក់ព័ន្ធនឹងការគ្រប់គ្រងប្រតិបត្តិការនៃការនាំចេញ នាំចូលទំនិញ ។

២. កំណត់តួនាទីនិងការទទួលខុសត្រូវទាំងឡាយរបស់ស្ថាប័ន ដើម្បីធានាឱ្យបានថា ស្ថាប័នទាំងឡាយរក្សាកិច្ចសហប្រតិបត្តិការក្នុងកម្រិតខ្ពស់ និង ពុំមានសកម្មភាពត្រួតគ្នា ។

៣. សម្របសម្រួលផែនការ និងសកម្មភាពជាយុទ្ធសាស្ត្រទាក់ទិននឹងការគ្រប់គ្រងប្រតិបត្តិការនៃការនាំចេញ នាំចូលទំនិញ ដែលរួមមាន កិច្ចព្រមព្រៀងលើគោលដៅរួម ។



W

៤. ពិនិត្យឡើងវិញនូវនីតិវិធីសម្រាប់ការបញ្ចេញទំនិញ និងត្រួតពិនិត្យទំនិញពាណិជ្ជកម្មអន្តរជាតិ និងតាមការចាំបាច់បង្កើតនីតិវិធីដែលមានប្រសិទ្ធិភាព សម្រាប់ការអនុវត្តន៍ ទន្ទឹមគ្នានឹងការដាក់ឱ្យអនុវត្តវិធីបញ្ចេញទំនិញតាមប្រព័ន្ធអេឡិកត្រូនិក ។

៥. រៀបចំ និងតាមដានត្រួតពិនិត្យការអនុវត្តន៍សេចក្តីណែនាំរដ្ឋបាលសម្រាប់ការត្រួតពិនិត្យ និងការបញ្ចេញទំនិញនាំចូល និងនាំចេញ ។

៦. ផ្សព្វផ្សាយអំពីតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័ន ដើម្បីផ្តល់ជូនសហគមន៍ពាណិជ្ជកម្មអន្តរជាតិនូវការយល់ដឹងច្បាស់លាស់អំពីដំណើរការពាក់ព័ន្ធនឹងប្រតិបត្តិការនៃការនាំចេញ នាំចូល ។

៧. ឃ្លាំមើលប្រសិទ្ធិភាពនៃនីតិវិធីសម្រាប់ការបញ្ចេញ និងត្រួតពិនិត្យទំនិញពាណិជ្ជកម្មអន្តរជាតិ ដោយប្រើប្រាស់ការគ្រប់គ្រងហានិភ័យ និងផ្តួចផ្តើមសកម្មភាពកែតម្រូវតាមការចាំបាច់ ។

## មាត្រា ២.-

ក្រុមសម្របសម្រួលអន្តរស្ថាប័ននេះត្រូវបានដឹកនាំដោយប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ ហើយសមាជិកភាពរួមមាន :

- តំណាងទីចាត់ការគយ និងរដ្ឋាករ
- តំណាងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញអាហារ័ណ នីហារ័ណ និងបង្រ្កាបការក្លែងបន្លំ (កាំកុងត្រូល)
- តំណាងស្ថាប័នពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម
- តំណាងក្រសួងសុខាភិបាល
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- តំណាងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- តំណាងស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធដទៃទៀតដែលនឹងត្រូវបានកំណត់ដោយអនុក្រឹត្យ ។

ក្រុមសម្របសម្រួលនេះ ត្រូវរាយការណ៍ជូនអនុគណៈកម្មាធិការកិច្ចសម្រួលពាណិជ្ជកម្ម និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីចាត់ការគយ និងរដ្ឋាករ ។



W

**មាត្រា ៣.-**

សម្រាប់គោលបំណងនៃអនុក្រឹត្យនេះ សមាជិកនៃក្រុមសម្របសម្រួលអន្តរស្ថាប័ន ត្រូវបានហៅថា "តំណាងស្ថាប័នឯកទេស" ។

## ជំពូកទី ២

## នីតិវិធីរដ្ឋបាល

**មាត្រា ៤.-**

ព័ត៌មានពាក់ព័ន្ធនឹងទំនិញនិងប្រតិវេទន៍ ត្រូវដាក់ជូនទីចាត់ការគយនិងរដ្ឋាករ ។ មុនពេលដាក់ឱ្យអនុវត្តការបញ្ជូនទិន្នន័យតាមប្រព័ន្ធអេឡិកត្រូនិក ពាណិជ្ជករត្រូវបានតម្រូវឱ្យដាក់ប្រតិវេទន៍គយ និងឯកសារពាក់ព័ន្ធឯទៀតតែមួយច្បាប់ប៉ុណ្ណោះ ។

ក្រោយពេលមានប្រព័ន្ធបញ្ជូនទិន្នន័យអេឡិកត្រូនិកពាណិជ្ជករដែលផ្តល់ទិន្នន័យតាមប្រព័ន្ធអេឡិកត្រូនិក នឹងមិនត្រូវបានតម្រូវឱ្យដាក់ជូនព័ត៌មានជាក្រដាសស្នាមទៀតឡើយ ។

**មាត្រា ៥.-**

ទីចាត់ការគយ និងរដ្ឋាករគឺជាស្ថាប័ននាំមុខតែមួយគត់ ដែលទទួលខុសត្រូវលើការត្រួតពិនិត្យទំនិញនៅមាត់ច្រកអន្តរជាតិ ។ ក្នុងករណីដែលតម្រូវឱ្យមានការត្រួតពិនិត្យដោយស្ថាប័នផ្សេងទៀតស្របតាមការកំណត់រកឃើញហានិភ័យ ការត្រួតពិនិត្យនេះត្រូវធ្វើឡើងរួមគ្នាតែមួយលើកជាមួយគ្នា ក្រោមការសម្របសម្រួលរបស់ទីចាត់ការគយ និងរដ្ឋាករ ។

**មាត្រា ៦.-**

ផ្អែកលើទ្រង់ទ្រាយនៃហានិភ័យ និងសេចក្តីណែនាំរដ្ឋបាលដែលត្រូវបានបង្កើតឡើងតាមការណែនាំរបស់ក្រុមសម្របសម្រួលអន្តរស្ថាប័ន ទីចាត់ការគយ និងរដ្ឋាករនឹង :

១. បញ្ចេញទំនិញ

២. ចាត់វិធានការដាក់លាក់ (ឧទាហរណ៍ ពិនិត្យឯកសារបន្ថែម ស្កេន ឬ ធ្វើអធិការកិច្ចជារូបវ័ន្ត) នៅទីណាដែលស្ថិតនៅក្នុងភារកិច្ចនិងសមត្ថកិច្ចរបស់ខ្លួន ក្នុងការធ្វើដូច្នេះ ឬ

៣. បញ្ជូនព័ត៌មានលំអិតអំពីទំនិញទៅឱ្យស្ថាប័នឯកទេសដទៃទៀត ដើម្បីពិចារណាលើភាពចាំបាច់ឱ្យមានព័ត៌មានបន្ថែមទៀត ដើម្បីឱ្យទីចាត់ការគយនិងរដ្ឋាករអាចធ្វើអធិការកិច្ច តាងនាមស្ថាប័នទាំងនោះ ឬ ដើម្បីចាត់វិធានការដាក់លាក់ផ្សេងទៀត ។

## មាត្រា ៧.-

កាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទទួលបន្ទុករួមលើទំនិញ ឬផលិតផលជាក់លាក់ដែលត្រូវបានកំណត់នៅពេលណាមួយដោយរាជរដ្ឋាភិបាលកម្ពុជា ។ ចំពោះផលិតផលទាំងនេះ ជាទូទៅតំណាងស្ថាប័នឯកទេសទទួលបន្ទុកលើការធានាឱ្យបាននូវការគោរពតាមកាតព្វកិច្ចអន្តរជាតិ ការគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាតិ ដែលគ្រប់គ្រងការចាត់ចែងផលិតផលទាំងនេះ និងដែលគ្រប់គ្រងហានិភ័យដើម្បីសម្រេចឱ្យបាននូវគោលដៅទាំងនេះ ។ ស្ថាប័នទាំងនេះនឹងបង្កើតលក្ខណៈវិនិច្ឆ័យជ្រើសរើសច្បាស់លាស់ផ្អែកលើហានិភ័យសម្រាប់ទំនិញជាក់លាក់ទាំងនេះ ។

## មាត្រា ៨.-

នៅពេលដែលមានការកំណត់ថា ទំនិញគឺជា :

- ទំនិញដែលត្រូវបានហាមឃាត់ ឬជាប់កម្រិតកំណត់
- ទំនិញដែលត្រូវបានកំណត់ថាមានហានិភ័យខ្ពស់
- ទំនិញដែលជាកម្មវត្ថុនៃការតម្រូវនានារបស់ស្ថាប័នដទៃទៀត

ទំនិញទាំងនេះ នឹងត្រូវបានកំណត់ឱ្យធ្វើការត្រួតពិនិត្យមុនពេលបញ្ចេញទំនិញ និងអនុញ្ញាតឱ្យយកចេញ ។ កិច្ចតម្រូវនានារបស់ស្ថាប័នទាំងអស់ត្រូវបានបំពេញតាមរយៈការត្រួតពិនិត្យតែមួយលើក និងមិនត្រូវធ្វើការត្រួតពិនិត្យត្រួតគ្នាឡើយ ។

**មាត្រា ៩.-**

គ្រប់ករណីទាំងអស់ ការសម្រេចចិត្តត្រួតពិនិត្យទំនិញជារូបវ័ន្ត ត្រូវផ្អែកលើហានិភ័យដែលបានកំណត់រកឃើញ និងត្រូវធ្វើការត្រួតពិនិត្យតែមួយលើក ។ ទីចាត់ការគយ និងរដ្ឋាករ ត្រូវរៀបចំរបាយការណ៍នៃការត្រួតពិនិត្យនេះ ។

## ជំពូកទី ៣

## កិច្ចព្រមព្រៀងអន្តរស្ថាប័ន

**មាត្រា ១០.-**

កិច្ចព្រមព្រៀងអន្តរស្ថាប័ននឹងត្រូវដាក់ឱ្យអនុវត្តរវាងទីចាត់ការគយ និងរដ្ឋាករ និងតំណាងស្ថាប័នឯកទេសដទៃទៀតរួមមាន កាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដែលកំណត់បញ្ជាក់លំអិតអំពីតួនាទី និងការទទួលខុសត្រូវរៀង១ខ្លួន ។

**មាត្រា ១១.-**

កិច្ចព្រមព្រៀងអន្តរស្ថាប័នត្រូវចែងពីកាលៈទេសៈ ដែលទីចាត់ការគយ និងរដ្ឋាករត្រូវបញ្ជូនព័ត៌មានលំអិតនៃទំនិញទៅឱ្យតំណាងស្ថាប័នឯកទេស និងវិធីនៃការបញ្ជូននេះ ។

**មាត្រា ១២.-**

កិច្ចព្រមព្រៀងអន្តរស្ថាប័ននឹងកំណត់ផលិតផល និងមុខទំនិញជាក់លាក់នានាដែលតំណាងស្ថាប័នឯកទេសត្រូវបានប្រគល់ឱ្យទទួលខុសត្រូវខាងគោលនយោបាយដោយរាជរដ្ឋាភិបាល តាមរយៈការធ្វើចំណាត់ថ្នាក់ទំនិញក្នុងកំរិតលេខប្រាំបីខ្ទង់នៃតារាងពន្ធគយកម្ពុជាជាធរមាន ដែលត្រូវចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៣.-**

កិច្ចព្រមព្រៀងរដ្ឋបាលត្រូវតែធានាឱ្យបានថា ការសម្រេចចិត្តធ្វើការត្រួតពិនិត្យទំនិញគឺផ្អែកលើហានិភ័យ ដែលត្រូវបានកំណត់ដោយអនុលោមតាមអនុក្រឹត្យនេះ ។

**មាត្រា ១៤.-**

នៅពេលដែលតំណាងស្ថាប័នឯកទេសទទួលខុសត្រូវលើការគ្រប់គ្រងប្រតិបត្តិការនាំចេញ នាំចូលទំនិញ តម្រូវឱ្យមានជំនាញឯកទេសជាក់លាក់ ដែលមិនមាននៅក្នុងទីចាត់ការគយ និងរដ្ឋាករ និងកាំកុងត្រូល នោះអ្នកឯកទេសពីស្ថាប័នពាក់ព័ន្ធត្រូវបានចាត់ឱ្យបំពេញការងារ តាមសំណើរបស់ទីចាត់ការគយ និងរដ្ឋាករ ។

## ជំពូកទី ៤

## នីតិវិធីប្រតិបត្តិការផ្អែកលើហានិភ័យ

**មាត្រា ១៥.-**

ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវរៀបចំ និងអនុម័តនីតិវិធីប្រតិបត្តិការផ្អែកលើហានិភ័យ ចំពោះការនាំចូល ការនាំចេញ ការដឹកជញ្ជូន ការទុកដាក់ទំនិញ អនុលោមតាមគោលការណ៍ខាងក្រោមនេះ :

១. មានតែទំនិញណាដែលត្រូវបានកំណត់ថា អាចមានហានិភ័យខ្ពស់តែប៉ុណ្ណោះដែលត្រូវបានជ្រើសរើសសម្រាប់ការត្រួតពិនិត្យ ។ ការត្រួតពិនិត្យពុំត្រូវធ្វើហួសពីអ្វីដែលចាំបាច់ដើម្បីបញ្ជាក់អះអាង ឬបដិសេធការវាយតម្លៃដំបូងឡើយ ។

២. ចំពោះឯកសារពាណិជ្ជកម្ម :

- ល័ក្ខខ័ណ្ឌឯកសារពាណិជ្ជកម្មត្រូវមានលក្ខណៈអប្បបរិមា ដែលចាំបាច់សម្រាប់ឱ្យអាជ្ញាធរអាចអនុវត្តបានតាមការទទួលខុសត្រូវរបស់ខ្លួន
- ឯកសារត្រូវបានកំណត់ឱ្យដាក់ជូនតែមួយដង
- ពាណិជ្ជករអាចដាក់ជូនឯកសារបញ្ចេញទំនិញនៅចំណុចនាំចូល នាំចេញ ឬចំណុចបញ្ចេញទំនិញ ។

៣. ការត្រួតពិនិត្យឯកសារនាំចូល ឬនាំចេញត្រូវបានធ្វើមុនការត្រួតពិនិត្យជារូបវ័ន្តលើទំនិញ ។ ការងារនេះអាចបញ្ជាក់អះអាង ឬបដិសេធការបារម្ភអំពីលទ្ធភាពនៃហានិភ័យ ។

៤. ការពិនិត្យវិភាគ និង ការអនុញ្ញាតឱ្យបញ្ចេញទំនិញមុនពេលមកដល់ ត្រូវអនុវត្តនៅពេលដែលពាណិជ្ជករមានលទ្ធភាពផ្តល់ឯកសារសមស្របមុនពេលទំនិញមកដល់ ។

៥. សវនកម្មក្រោយពេលបញ្ចេញទំនិញ ត្រូវបានប្រើនៅពេលណាដែលអាចធ្វើទៅបាន ។

៦. ទំនិញអាចត្រូវបានត្រួតពិនិត្យនៅក្រៅពីចំណុចត្រួតពិនិត្យព្រំដែន តាមកាលៈទេសៈសមស្រប ។

**មាត្រា ១៦.-**

ដើម្បីគាំទ្រដល់ការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធិភាព តំណាងស្ថាប័នឯកទេសទាំងអស់នឹងត្រូវបានផ្តល់លទ្ធភាពទទួលស្ថិតិនាំចូល និងនាំចេញ ដែលត្រូវបានប្រមូលដោយទីចាត់ការគយ និងរដ្ឋាករពាក់ព័ន្ធនឹងការនាំចូល និងនាំចេញទំនិញដែលស្ថាប័នទាំងនោះទទួលបន្ទុក ។

## ជំពូកទី ៥

## ចំណាត់ការលើការអនុវត្តន៍ ការត្រួតពិនិត្យ និង ការវាយតម្លៃ

**មាត្រា ១៧.-**

តំណាងស្ថាប័នឯកទេសទាំងអស់ត្រូវ :

១. ធ្វើការវាយតម្លៃលើស្ថានភាពគ្រប់គ្រងប្រតិបត្តិការនាំចេញ នាំចូលទំនិញ និងរៀបចំផែនការសកម្មភាព ដែលចែងពីវិស័យជាសក្តានុពលនៃកិច្ចសហប្រតិបត្តិការ និងកិច្ចសម្រួលរវាងស្ថាប័នពាក់ព័ន្ធទាំងឡាយ ។

២. រៀបចំ អនុវត្ត និងផ្សព្វផ្សាយ សេចក្តីណែនាំអន្តរស្ថាប័ន និងគាំទ្រតាមរយៈកិច្ចព្រមព្រៀងអន្តរស្ថាប័នជាផ្លូវការ ។

៣. កែសម្រួលនីតិវិធីប្រតិបត្តិការរបស់ខ្លួន ដើម្បីធានាឱ្យបានថាការបញ្ចេញទំនិញទាំងអស់គឺផ្អែកលើគោលការណ៍នៃការគ្រប់គ្រងហានិភ័យ សំដៅកាត់បន្ថយចំនួនអធិការកិច្ចដែលត្រូវធ្វើ ។

៤. ពិគ្រោះជាមួយវិស័យឯកជនអំពីគំនិតផ្តួចផ្តើមទាំងនេះ ។

**មាត្រា ១៨.-**

អនុគណៈកម្មាធិការកិច្ចសម្រួលពាណិជ្ជកម្ម នៃគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន ត្រូវមានភារៈកិច្ចឃ្លាំមើល និងវាយតម្លៃលើការអនុវត្តន៍អនុក្រឹត្យនេះ ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៩.-**

បទប្បញ្ញត្តិនាពេលអនាគតពាក់ព័ន្ធនឹងការត្រួតពិនិត្យនិងការបញ្ចេញទំនិញសម្រាប់ការនាំចូលនិងនាំចេញ ត្រូវមានសង្គតិភាពជាមួយនឹងគោលនយោបាយ និងយុទ្ធសាស្ត្រសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ ។

**មាត្រា ២០.-**

សេចក្តីណែនាំសម្រាប់ការអនុវត្តន៍ ការគ្រប់គ្រងហានិភ័យនៅតាមក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជាដែលពាក់ព័ន្ធនឹងបែបបទនាំចូល និងនាំចេញ មានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលគ្រប់ខេត្តក្រុង និងគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មិនា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២២
- ឯកសារ-កាលប្បវត្តិ

# <u>ឧបសម្ព័ន្ធ</u>

នៃអនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មិនា ឆ្នាំ២០០៦

## សេចក្តីណែនាំសម្រាប់ការអនុវត្តន៍ការគ្រប់គ្រងហានិភ័យនៅតាមក្រសួង និងស្ថាប័ន នៃរាជរដ្ឋាភិបាលកម្ពុជាដែលពាក់ព័ន្ធនឹងបែបបទនាំចូលនិងនាំចេញ

សេចក្តីណែនាំទាំងនេះ មានគោលបំណងឱ្យក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា អនុវត្តកម្មវិធីគ្រប់គ្រងហានិភ័យ ដែលនឹងកែលំអយ៉ាងច្រើននូវការសម្រួលពាណិជ្ជកម្ម សន្តិសុខ និងការគ្រប់គ្រងកិច្ចប្រតិបត្តិការនាំចេញនាំចូលទំនិញនៅតាមមាត់ច្រកព្រំដែនអន្តរជាតិ ។

រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការដ៏សំខាន់មួយ កំណត់ជាអាទិភាពនូវការអនុវត្តនីយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ និងយន្តការច្រកទ្វារតែមួយសម្រាប់ការត្រួតពិនិត្យការនាំចូល និងការនាំចេញទំនិញ ។ ក្នុងការកំណត់នេះ គ្រប់ក្រសួង និងស្ថាប័នទាំងឡាយត្រូវអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ ដែលផ្អែកលើគម្រូអន្តរជាតិដ៏ប្រសើរបំផុត និងបានបញ្ជាក់ថា នៅក្នុងអនាគត " ការសម្រេចក្នុងការត្រួតពិនិត្យទំនិញ ត្រូវផ្អែកលើការកំណត់ហានិភ័យស្របតាម បទដ្ឋានរដ្ឋបាលច្បាស់លាស់ " ។

ការកំណត់ក៏បានបញ្ជាក់ផងដែរថា ទីចាត់ការគយ និងរដ្ឋាករ គឺជាស្ថាប័ននាំមុខតែមួយគត់ដែលទទួលខុសត្រូវការត្រួតពិនិត្យទំនិញនៅតាមមាត់ច្រកអន្តរជាតិ ហើយក្នុងករណីដែលតម្រូវអោយមានការត្រួតពិនិត្យ ដោយស្ថាប័នផ្សេងទៀតស្របតាមការកំណត់រកឃើញហានិភ័យ ការត្រួតពិនិត្យនេះត្រូវធ្វើឡើងរួមគ្នាតែមួយលើកជាមួយគ្នាក្រោមការសំរបសំរួលរបស់ទីចាត់ការគយ និងរដ្ឋាករ ។

## <u>សាវតា</u>

ការគ្រប់គ្រងហានិភ័យគឺជាវិធីដ៏សមហេតុផលនិងជាប្រព័ន្ធមួយនៃការកំណត់ ការវិភាគ និងការគ្រប់គ្រងហានិភ័យ ។ នៅក្នុងបរិបថគ្រប់គ្រងព្រំដែនអន្តរជាតិ វាគឺជាការអនុវត្តនីជាប្រព័ន្ធនូវនីតិវិធីគ្រប់គ្រង និងសកម្មភាពទាំងឡាយ ដើម្បីផ្តល់ជូនស្ថាប័ននូវព័ត៌មានចាំបាច់ដើម្បីគ្រប់គ្រងចលនាឬទំនិញដែលមានហានិភ័យ ។

គេឃើញមានស្តង់ដារគ្រប់គ្រងហានិភ័យអន្តរជាតិដ៏ល្បីល្បាញមួយចំនួន ដែលត្រូវបានប្រើនៅក្នុងឧស្សាហកម្មផ្សេងៗ ដូចជាការធានារ៉ាប់រងនិងវិស្វកម្ម។ មូលដ្ឋានច្បាប់សម្រាប់ការអនុវត្តន៍ការគ្រប់គ្រងហានិភ័យនៅក្នុងបរិស្ថានគយ ត្រូវបានចែងនៅក្នុងជំពូក ៦ នៃឧបសម្ព័ន្ធទូទៅ[១] នៃអនុសញ្ញាក្យូតូដែលកែសម្រួលឡើងវិញ។ គំរូនៃការគ្រប់គ្រងហានិភ័យដែលត្រូវបានពិព័ណ៌នានៅក្នុងអនុសញ្ញានេះ គឺផ្អែកលើស្តង់ដារអូស្ត្រាលី/នូវ៉ែលសេឡង់ (AS/NZS 4360:1995) ដែលបានអនុម័តដោយអង្គការគយពិភពលោក ។

រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ឱ្យក្រសួងនិងស្ថាប័នរដ្ឋាភិបាលអនុវត្តគំរូអន្តរជាតិដ៏ប្រសើរបំផុតនៅក្នុងវិស័យគ្រប់គ្រងហានិភ័យ និង ក្នុងន័យនេះ រាជរដ្ឋាភិបាលមានបំណងឱ្យក្រសួងរដ្ឋាភិបាលទាំងអស់អនុម័តស្តង់ដារនេះ[២] ។ ប្រការនេះនឹងផ្តល់នូវសង្គតិភាពជាតិក្នុងកម្រិតមួយ ដែលគឺជាកូនសោរដ៏សំខាន់មួយចំពោះការអនុវត្តន៍ប្រកបដោយជោគជ័យនូវគំនិតផ្តួចផ្តើមនេះ ។

នៅក្នុងបរិការកម្ពុជា ការអនុវត្តន៍ការគ្រប់គ្រងហានិភ័យមានន័យថា ក្រសួងនិងស្ថាប័នទាំងអស់នឹងចាំបាច់ត្រូវរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងការផ្លាស់ប្តូរមួយ ដែលរួមមានការអប់រំនិងការបណ្តុះបណ្តាលការយល់ដឹងមួយកញ្ចប់សម្រាប់បុគ្គលិកទាំងអស់។ ការគាំទ្រផ្នែកនយោបាយកម្រិតខ្ពស់ និងការប្តេជ្ញាចិត្តរបស់សមត្ថកិច្ចអនុវត្ត គឺមានសារៈសំខាន់ក្រៃលែង ។

អនាគតការត្រួតពិនិត្យទាំងអស់នឹងត្រូវបានធ្វើឡើងតែម្តងគត់ ដោយមិនគិតពីចំនួននៃស្ថាប័នដែលមានការចាប់អារម្មណ៍លើទំនិញឡើយ។

បរិស្ថានប្រតិបត្តិការថ្មីនេះនាំមកនូវទស្សនាទានដែលស្ថាប័នគោលនយោបាយអាចកំណត់ ថាតើគេចាំបាច់ត្រូវមានសេវាកម្មអ្វីខ្លះនៅតាមទីស្នាក់ការត្រួតពិនិត្យព្រំដែនអន្តរជាតិ ថាតើសេវាកម្មនេះនឹងត្រូវបានផ្តល់យ៉ាងដូចម្តេច និង បែបបទរាយការណ៍ដែលគប្បីអមការត្រួតពិនិត្យ។ ក្រសួងឬស្ថាប័នគោលនយោបាយ គឺជា "អ្នកទទួលសេវា" ហើយស្ថាប័នទាំងឡាយ ដូចជាទីចាត់ការគយនិងរដ្ឋាករ និង កាំកុងត្រូល គឺជា "អ្នកផ្តល់សេវា" ។

[១] អត្ថបទដកស្រង់នៅក្នុងឧបសម្ព័ន្ធ ២

[២] ស្តង់ដារអូស្ត្រាលី/នូវ៉ែលសេឡង់ (AS/NZS 4360:2004)

# ការអនុវត្តន៍ការគ្រប់គ្រងហានិភ័យ

ស្ថាប័នត្រួតពិនិត្យតាមព្រំដែនភាគច្រើន មិនចង់ឈានទៅកាន់បរិស្ថានចាត់ចែងមួយ ដែលពាក់ព័ន្ធនឹងការបញ្ចេញទំនិញដោយគ្មានការត្រួតពិនិត្យ ។ ប៉ុន្តែ ខណៈដែលពាណិជ្ជកម្មកើនឡើង ហើយកិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់កើនឡើងទ្វេគុណ គេពុំឃើញមានជម្រើសភ្លាមៗចំពោះការគ្រប់គ្រងហានិភ័យឡើយ ប្រសិនបើរដ្ឋាភិបាលចង់ការពារសន្តិសុខព្រំដែន និង កែលំអនីតិវិធីបញ្ចេញទំនិញ និង គំនិតផ្តួចផ្តើមធ្វើពាណិជ្ជកម្មតំបន់។

ស្ថាប័នត្រួតពិនិត្យនៅតាមព្រំដែនត្រូវប្រកាន់យកវិធីប្រតិបត្តិការនៅក្នុងបរិស្ថានថ្មីនេះ ។ ការជ្រើសរើសទំនិញ មធ្យោបាយដឹកជញ្ជូន ឬឯកសារដើម្បីត្រួតពិនិត្យ ត្រូវតែផ្អែកលើទម្រង់ហានិភ័យដែលមាន មុខព្រួញប្រតិបត្តិការជាក់លាក់ ។ នីតិវិធីជម្រើសនេះក៏អាចអនុញ្ញាតផងដែរឱ្យមានការជ្រើសរើសដោយចោះៗផ្អែកលើការជ្រើសរើសគម្រូស្ថិតិ ឬគំនិតរបស់មន្ត្រីផ្អែកលើបទពិសោធន៍ ឬការសង្ស័យ ។ ប្រតិបត្តិការអាចត្រូវបានកំណត់ផ្អែកលើមូលដ្ឋាននៃប្រវត្តិហានិភ័យមួយចំនួន ។

ការជ្រើសរើសបុគ្គល និងក្រុមហ៊ុនដើម្បីធ្វើសវនកម្ម ក៏អាចផ្អែកលើប្រវត្តិហានិភ័យផងដែរ។ សវនកម្មអាចត្រូវបានធ្វើឡើងដើម្បីគោលបំណងពិនិត្យមើលការគោរពច្បាប់នៅក្នុងវិស័យនៃការកំណត់តម្លៃគិតពន្ធ ដើមកំណើតទំនិញ ចំណាត់ថ្នាក់ទំនិញ កម្មវិធីលើកលែងពន្ធ ការបង្វិលសងវិញ ។ល។ ប៉ុន្តែគួរយកចិត្តទុកដាក់លើវិស័យដទៃទៀតតាមការចាំបាច់ ។ អាស្រ័យលើប្រវត្តិនៃក្រុមហ៊ុន ឬបុគ្គលដែលត្រូវបានធ្វើសវនកម្ម សវនកម្មនេះអាចត្រូវបានធ្វើលើមូលដ្ឋានជា បន្តបន្ទាប់ ទៀងទាត់ ឬ ម្តងម្កាល។ នៅក្រោយពេលដែលស្ថាប័នមួយបានអនុម័តយកគំនិតនៃការគ្រប់គ្រងហានិភ័យ វានឹងក្លាយទៅជាផ្នែកមួយដ៏សំខាន់នៃការជ្រើសរើស ការកំណត់ប្រវត្តិ និងការកំណត់មុខសញ្ញាដើម្បីការវាយតម្លៃហានិភ័យ។

លក្ខណៈវិនិច្ឆ័យជ្រើសរើសទំនិញដែលត្រូវបង់ពន្ធគយ អាចរួមមានប្រវត្តិរបស់អ្នកនាំចូល អ្នកនាំចេញ ក្រុមហ៊ុនដឹកជញ្ជូន ភ្នាក់ងារ ។ល។ ប្រភពនិងការបញ្ជូនទំនិញ និង ការហាមឃាត់ ការដាក់កំហិត ឬ បញ្ហាដោយឡែកដែលប៉ះពាល់លើហានិភ័យ។

សូចនាករហានិភ័យគឺជាលក្ខណៈវិនិច្ឆ័យជ្រើសរើសជាក់លាក់ដូចជា លេខកូដទំនិញជាក់លាក់ ប្រទេសដើមកំណើតទំនិញ និងតម្រាយផ្លូវនៃទំនិញ សូចនាករអាជ្ញាប័ណ្ណ តម្លៃ ពាណិជ្ជករ កម្រិតនៃការគោរពច្បាប់ [illegible]

មធ្យោបាយដឹកជញ្ជូន គោលបំណងនៃការស្នាក់នៅក្នុងដែនគយ ផលវិបាកហិរញ្ញវត្ថុ និងស្ថានភាពហិរញ្ញវត្ថុរបស់ពាណិជ្ជករ និងបុគ្គល ។

ការកំណត់ប្រវត្តិហានិភ័យគឺជាមធ្យោបាយដែលស្ថាប័នព្រំដែនអនុវត្តជាក់ស្តែងនូវការគ្រប់គ្រងហានិភ័យ ។វាជំនួសរបបទាំងឡាយដែលតម្រូវឱ្យមានការត្រួតពិនិត្យទំនិញ ១០០% ជាមួយនឹងការត្រួតពិនិត្យឯកសារ និងទំនិញក្នុងលក្ខណៈជាប្រព័ន្ធនិងវិទ្យាសាស្ត្រ ដែលបង្កើនជាអតិបរិមានូវការប្រើប្រាស់ធនធានស្ថាប័នព្រំដែន និង ដែលផ្តល់ការសម្រួលពាណិជ្ជកម្មជាអតិបរិមា។

ប្រវត្តិហានិភ័យអាចរួមមានវិស័យដែលមានហិភ័យ ការវាយតម្លៃហានិភ័យ វិធានការទប់ទល់ដែលនឹងត្រូវអនុវត្ត កាលបរិច្ឆេទសកម្មភាព លទ្ធផលនិងការវាយតម្លៃប្រសិទ្ធិភាពនៃសកម្មភាពដែលបានអនុវត្ត។ ព័ត៌មាននេះគឺជាលទ្ធផលនៃគោលនយោបាយកម្ពុជា និង ក្រសួងនិងស្ថាប័នប្រតិបត្តិការដែលឈានទៅកាន់ការអនុវត្តន៍អភិក្រមផ្អែកលើហានិភ័យចំពោះការសម្រួលពាណិជ្ជកម្មអន្តរជាតិ និង ការគ្រប់គ្រងព្រំដែន។

ក្រោយពេលត្រូវបានបង្កើតរួចហើយ ប្រវត្តិរួមជាមួយនឹងព័ត៌មានដទៃទៀត នឹងផ្តល់នូវមូលដ្ឋានសម្រាប់ផ្តោតមុខសញ្ញាលើចលនាទំនិញនិងមធ្យោបាយដឹកជញ្ជូនដែលមានសក្តានុពលហានិភ័យខ្ពស់ ។

វិស័យឯកជន រួមមានអ្នកនាំចូល អ្នកនាំចេញ ក្រុមហ៊ុនដឹកជញ្ជូន និង ជើងសារគយ គឺជាកត្តាដ៏សំខាន់មួយចំពោះជោគជ័យនៃអភិក្រមផ្អែកលើហានិភ័យចមពោះការចាត់ចែងការបញ្ចេញទំនិញ។

ការផ្តល់ព័ត៌មានស្តីពីល័ក្ខខ័ណ្ឌឯកសារ និងល័ក្ខខ័ណ្ឌបញ្ចេញទំនិញជូនដល់វិស័យឯកជន គឺជាកត្តាគន្លឹះមួយនៅក្នុងការអនុវត្តន៍ប្រព័ន្ធផ្អែកលើហានិភ័យដ៏រឹងមាំ ។ "ការគោរពច្បាប់ដែលមានប្រកបដោយព័ត៌មានគ្រប់គ្រាន់" គឺជាពាក្យដែលត្រូវបានប្រើជាអន្តរជាតិ នៅពេលនិយាយដល់តួនាទីរបស់អតិថិជនរបស់ស្ថាប័នត្រួតពិនិត្យតាមព្រំដែន។ ស្ថាប័នត្រួតពិនិត្យតាមព្រំដែនតប្បីរំពឹងថា អ្នកនាំចូល អ្នកនាំចេញ ក្រុមហ៊ុនដឹកជញ្ជូន និង ជើងសារគយ ត្រូវគោរពតាមច្បាប់ទាក់ទិននឹងការ នាំចូលនិងការនាំចេញទំនិញ ប្រសិនបើព័ត៌មាននេះគឺជាព័ត៌មានសាធារណៈ និងត្រូវបានធ្វើឱ្យទាន់សម័យផ្អែកលើតម្រូវការ ។

# សេចក្តីណែនាំ

## សេចក្តីណែនាំទី ១: ការអនុវត្តន៍ការគ្រប់គ្រងហានិភ័យ

ក្រសួង និងស្ថាប័នទាំងអស់នឹងអនុវត្តរបបការគ្រប់គ្រងហានិភ័យនៅក្នុងអង្គភាពរបស់ខ្លួន និងអនុលោមទៅតាមស្តង់ដារអូស្ត្រាលី/ញូវែលហ្សេឡង់ (អូស្ត្រាលី/ ញូវែលហ្សេឡង់ ៤៣៦០:២០០៤) ដែលបានអនុម័តដោយអង្គការគយពិភពលោក ។ ការបង្កើតអង្គភាពការគ្រប់គ្រងហានិភ័យនឹងផ្តល់ជំនាញក្នុងអង្គភាពខ្លួនតែម្តង ដើម្បីរៀបចំការបណ្តុះបណ្តាលការយល់ដឹងដល់មន្ត្រី និងជំនាញការដើម្បីបង្កើតផែនការប្រតិបត្តិការការគ្រប់គ្រងហានិភ័យ ។

## សេចក្តីណែនាំទី ២ : ការបង្កើត និងទំនាក់ទំនងនៃប្រវត្តិ និងគោលដៅនៃការគ្រប់គ្រងហានិភ័យ

ស្ថាប័ននីមួយៗនឹងបង្កើតផែនការលំអិតនៃការគ្រប់គ្រងហានិភ័យ (សេចក្តីណែនាំទី ១) ដើម្បីកំណត់ទំនិញដែលមានហានិភ័យខ្ពស់ ឬមធ្យោបាយដឹកជញ្ជូនឆ្លងកាត់ព្រំដែនអន្តរជាតិ ។ ដំណើរការវាយតម្លៃហានិភ័យ រាប់បញ្ចូលការបង្កើត និងការអនុវត្តន៍ការឃ្លាំមើលនៅក្នុងស្រុក និងកម្មវិធីអនុលោមភាព ។

## សេចក្តីណែនាំទី ៣ : តួនាទីនៃស្ថាប័ននាំមុខតែមួយគត់ ដែលទទួលខុសត្រូវការត្រួតពិនិត្យទំនិញនៅទីស្នាក់ការត្រួតពិនិត្យព្រំដែនអន្តរជាតិ

ទីចាត់ការគយ និងរដ្ឋាករ គឺជាស្ថាប័ននាំមុខតែមួយគត់ដែលទទួលខុសត្រូវការត្រួតពិនិត្យទំនិញនៅតាមមាត់ច្រកអន្តរជាតិ ហើយក្នុងករណីដែលតម្រូវអោយមានការត្រួតពិនិត្យ ដោយ ស្ថាប័នផ្សេងទៀតស្របតាមការកំណត់រកឃើញហានិភ័យ ការត្រួតពិនិត្យនេះត្រូវធ្វើឡើងរួមគ្នាតែមួយ លើកជាមួយគ្នាក្រោមការសំរបសំរួលរបស់ទីចាត់ការ គយ និងរដ្ឋាករ ។

## សេចក្តីណែនាំទី ៤ : កិច្ចព្រមព្រៀងអន្តរស្ថាប័ន

កិច្ចព្រមព្រៀងអន្តរស្ថាប័នត្រូវបានបង្កើតដើម្បីធ្វើឱ្យការរៀបចំរវាងស្ថាប័នគោល នយោបាយ និងស្ថាប័នប្រតិបត្តិមានលក្ខណៈជាផ្លូវការ ។ ឯកសារនេះបានរៀបរាប់ពីគោលបំណងចម្បងរបស់ក្រសួង និងស្ថាប័ននីមួយៗ ដែលចាត់តាំងសេវាកម្មដែលតំរូវឱ្យមាននៅច្រកព្រំដែនអន្តរជាតិ និងសេវាកម្មដែលនឹង ផ្តល់ដោយស្ថាប័នព្រំដែន ។

## សេចក្តីណែនាំទី ៥ : បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់

ក្រសួង និងស្ថាប័ននីមួយៗដែលមានការទទួលខុសត្រូវផ្នែកគោលនយោបាយលើ ទំនិញហាមឃាត់ និងទំនិញជាប់កំរិតកំណត់នឹងត្រូវបង្កើតបញ្ជីមេមួយសំរាប់ដាក់ជូនទីចាត់ការគយ និងរដ្ឋាករ ។ បញ្ជីនេះនឹងបញ្ជាក់ពីសកម្មភាពដែលត្រូវអនុវត្តដោយស្ថាប័នត្រួតពិនិត្យតាមព្រំដែនពេលមានទំនិញនាំចូល ឬនាំចេញ ។

ទីចាត់ការគយ និងរដ្ឋាករនឹងធ្វើចំណាត់ថ្នាក់ទំនិញអនុលោមទៅតាមប្រព័ន្ធស៊ីចង្វាក់ផ្អែកលើតារាងពន្ធគយកម្ពុជា ។

បញ្ជីមេនៃទំនិញដែលបានធ្វើចំណាត់ថ្នាក់នេះនឹងត្រូវផ្តល់ជូនទៅគ្រប់ទីស្នាក់ការត្រួតពិនិត្យព្រំដែនអន្តរជាតិ និងបញ្ចូលទៅក្នុងម៉ូឌុលការគ្រប់គ្រងហានិភ័យនៃស្វ័យប្រវត្តិកម្មកិច្ចការគយ ( ASYCUDA) ។

ស្ថាប័នគោលនយោបាយនឹងតាមដានបញ្ជីមេនេះជាបន្តបន្ទាប់ ហើយបើចាំបាច់ត្រូវទាក់ទងទៅទីចាត់ការគយ និងរដ្ឋាករដើម្បីបន្ថែម ឬលុបចោលមុខទំនិញនៅក្នុងបញ្ជីនេះ ។

## សេចក្តីណែនាំទី ៦ : ការឃ្លាំមើល និងការរាយការណ៍

ទីចាត់ការគយ និងរដ្ឋាករ និងកាំកុងត្រូលនឹងប្រមូលពត៌មានរួមគ្នានូវចំនួនប្រតិវេទន៍ដែលបានទទួល និងបានអនុវត្តការត្រួតពិនិត្យពិនិត្យទំនិញជារូបវ័ន្តជាយថាហេតុ ។ ព័ត៌មាននឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ និងរៀបចំរបាយការណ៍រួចផ្ញើរជូននាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីដែលមានតំណាងនៅក្នុងក្រុមសម្របសម្រួលអន្តរ ក្រសួងរៀងរាល់ខែ ។ របាយការណ៍គប្បីរៀបរាប់ឱ្យលំអិតពីការចម្រើនទៅមុខធៀបទៅនឹងគោលដៅកំណត់ការកាត់បន្ថយការត្រួតពិនិត្យដែលរាជរដ្ឋាភិបាលបានកំណត់មិនច្រើនជាង ហាសិបភាគរយ នៃចំនួនប្រតិបត្តិការនាំចេញ-នាំចូលនៅដំណាច់ឆ្នាំ ២០០៦ និងមិនច្រើនជាងម្ភៃប្រាំភាគរយ នៅដំណាច់ឆ្នាំ ២០០៧ ។

# ការពន្យល់សេចក្តីណែនាំ

**សេចក្តីណែនាំទី ១ :**

ក្រសួង និងស្ថាប័នទាំងអស់នឹងអនុវត្តរបបការគ្រប់គ្រងហានិភ័យនៅក្នុងអង្គភាព របស់ ខ្លួន និងអនុលោមទៅតាមស្តង់ដារអូស្ត្រាលី/ណូវ៉ែលហ្សេឡង់ (អូស្ត្រាលី/ ណូវ៉ែលហ្សេឡង់ ៤៣៦០:២០០៤) ដែលអនុម័តដោយអង្គការគយពិភពលោក ។ ការបង្កើតអង្គភាពការគ្រប់គ្រងហានិភ័យនឹងផ្តល់ជំនាញ ក្នុង អង្គភាពខ្លួនតែម្តងដើម្បីរៀបចំការបណ្តុះបណ្តាលការយល់ដឹងដល់មន្ត្រី និងជំនាញការដើម្បីបង្កើតផែនការ ប្រតិបត្តិការការគ្រប់គ្រងហានិភ័យ ។

(១) ស្ថាប័នទាំងអស់នឹងបំពេញ និងពិនិត្យឡើងវិញជាបន្តបន្ទាប់នូវផែនការការគ្រប់គ្រងហានិភ័យជាយុទ្ធសាស្ត្ររបស់ខ្លួន [៣] ។ ឯកសារនេះរៀបរាប់ពីហានិភ័យជាយុទ្ធសាស្ត្រដែលបានកំណត់ដោយស្ថាប័នទាំងអស់ដែលមានការទទួលខុសត្រូវផ្នែកគោលនយោបាយ និងការអនុវត្តន៍ចំពោះទំនិញដែលឆ្លងកាត់ព្រំដែនអន្តរជាតិ ។

(២) ផែនការការគ្រប់គ្រងហានិភ័យជាយុទ្ធសាស្ត្រគប្បីត្រូវថតចម្លង និងចែកជូនទៅគ្រប់វិស័យការងារដែលនៅក្នុងក្រសួង ឬស្ថាប័ន ។

(៣) ស្ថាប័ន ឬនាយកដ្ឋាននីមួយៗនឹងបង្កើតអង្គភាពការគ្រប់គ្រងហានិភ័យមួយដែលទទួលខុសត្រូវក្នុងការបង្កើត និងការសម្របសម្រួលផែនការការគ្រប់គ្រងហានិភ័យ និងការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងហានិភ័យ ។

(៤) អង្គភាពការគ្រប់គ្រងហានិភ័យនឹងជួយវិស័យការងារទាំងអស់ដើម្បីរៀបចំផែនការការអនុវត្តន៍ការគ្រប់គ្រងហានិភ័យ ។ ផែនការទាំងនេះនឹងកំណត់ទំនិញដែលមានហានិភ័យខ្ពស់ព្រមទាំងអនុសាសន៍ក្នុងការកំចាត់ហានិភ័យ ។ ព័ត៌មាននេះនឹងត្រូវផ្តល់ជូនទីចាត់ការគយ និងរដ្ឋាករ ក្នុងទំរង់មួយដែលអាចទទួលយកបាន ។

(៥) ពេលដែលព័ត៌មានជាកលយុទ្ធជាក់លាក់ណាមួយមានការប៉ះពាល់ដល់ការនាំចូល ឬនាំចេញ ដែលស្ថាប័នគោលនយោបាយមួយបានផ្តល់ជូន. ព័ត៌មាននេះគប្បីផ្តល់ជូនទៅទីចាត់ការគយ និងរដ្ឋាករ ដោយបញ្ជាក់ពីការណែនាំយ៉ាងលំអិតអំពីសកម្មភាពណាមួយដែលតម្រូវឱ្យធ្វើនៅទីស្នាក់ការត្រួតពិនិត្យព្រំដែនអន្តរជាតិ ។ ទីចាត់ការគយ និងរដ្ឋាករ នឹងផ្តល់របាយការណ៍លំអិតមួយជូនទៅស្ថាប័នដែលបានផ្តល់ព័ត៌មានខាងលើពីលទ្ធផលនៃការពិនិត្យណាមួយ ឬសកម្មភាពដែលបានអនុវត្ត ។

[៣] ផែនការការគ្រប់គ្រងហានិភ័យជាយុទ្ធសាស្ត្រត្រូវបានបញ្ចប់ក្នុងខែធ្នូ ឆ្នាំ២០០៥

**សេចក្តីណែនាំទី ២.**

ស្ថាប័ននីមួយៗនឹងបង្កើតផែនការលំអិតនៃការគ្រប់គ្រងហានិភ័យ (សេចក្តីណែនាំទី ១) ដើម្បីកំណត់ទំនិញដែលមានហានិភ័យខ្ពស់ ឬមធ្យោបាយដឹកជញ្ជូនឆ្លងកាត់ព្រំដែនអន្តរជាតិ ។ ដំណើរការវាយតម្លៃហានិភ័យនឹងរាប់បញ្ចូលការបង្កើត និងការអនុវត្តនីការឃ្លាំមើលនៅក្នុងស្រុក និងកម្មវិធីអនុលោមភាព ។

(១) ស្ថាប័ននីមួយៗនឹងបង្កើតផែនការការអនុវត្តនីការគ្រប់គ្រងហានិភ័យ ។

(២) ស្ថាប័នទាំងអស់នឹងបង្កើតផែនការឃ្លាំមើលនៅក្នុងស្រុក និងកម្មវិធីគោរពតាម[4] ។

(៣) ទាំងផែនការការគ្រប់គ្រងហានិភ័យ និងកម្មវិធីការឃ្លាំមើលនៅក្នុងស្រុកនឹងបង្កើតព័ត៌មានទាក់ទងទៅនឹងទំនិញ ដែលអាចមានបទល្មើសបទបញ្ញានាំចូល ។

(៤) ពេលវិភាគ. ពត៌មាននេះនឹងត្រូវបានបញ្ជូនទៅឱ្យទីចាត់ការគយ និងរដ្ឋាករ ក្នុងទំរង់ជាការកំណត់តម្លៃ ឬរបាយការណ៍ពត៌មានសំរាប់បញ្ចូលទៅក្នុងបញ្ជីនៅទីស្នាក់ការត្រួតពិនិត្យព្រំដែនដែលបានរួមបញ្ចូលគ្នា[5] ។

**សេចក្តីណែនាំទី ៣ :**

បទបញ្ញារបស់នាយករដ្ឋមន្ត្រីលេខ ៩០ តម្រូវឱ្យមានការត្រួតពិនិត្យទំនិញ ត្រូវផ្អែកលើប្រវត្តិហានិភ័យដែលបានកំណត់ ។ ទីចាត់ការគយ និងរដ្ឋាករជាអ្នកសម្របសម្រួលក្នុងការពិនិត្យទំនិញដើម្បីធានាថាគ្មានការត្រួតពិនិត្យត្រួតគ្នា ។

(១) អ្នកនាំចូល និងនាំចេញត្រូវបានតម្រូវឱ្យដាក់ឯកសារតែមួយច្បាប់តែប៉ុណ្ណោះ ។ ឯកសារទាំងនេះត្រូវតែដាក់ជូនឱ្យទីចាត់ការគយ និងរដ្ឋាករ ។

(២) ផ្អែកលើសាវតាហានិភ័យ និងបែបបទរដ្ឋបាលទាំងនេះទីចាត់ការគយ និងរដ្ឋាករ ត្រូវ:

- បញ្ចេញទំនិញ.
- ធ្វើសកម្មភាពជាក់លាក់ (ឧទាហរណ៍: ការពិនិត្យឯកសារបន្ថែមទៀត. ពិនិត្យតាមម៉ាស៊ីន Scan ឬធ្វើការពិនិត្យជារូបវ័ន្ត) កាលបើស្ថិតក្នុងអាណត្តិការងារ និងសមត្ថកិច្ចរបស់ខ្លួន
- បញ្ជូនព័ត៌មានលំអិតនៃទំនិញ ទៅឱ្យតំណាងស្ថាប័នឯកទេសផ្សេងទៀត សម្រាប់ធ្វើការពិចារណា អំពីតម្រូវការពត៌មានបន្ថែមទៀត ដើម្បីឱ្យទីចាត់ការគយ និងរដ្ឋាករធ្វើការត្រួតពិនិត្យជំនួស ឬត្រូវធ្វើសកម្មភាពជាក់លាក់ណាមួយទៀត ។ ប្រសិនបើតំណាងស្ថាប័នឯកទេសមិនឆ្លើយតបមកទីចាត់ការគយ

---

[4] ឧបសម្ព័ន្ធទី២មានការពន្យល់លំអិតបន្ថែមទៀតពីដំណើរការវិធានការណ៍គោរពតាម

[5] ភ្ជាប់ជូននូវទំនិញហាមឃាត់ និងមានកំរិត

និងរដ្ឋាករក្នុងរយៈពេលប្រាំបីម៉ោងក្រោយពេលបញ្ជូន ទីចាត់ការគយ និងរដ្ឋាករអាចចាត់វិធានការបានដោយឯករាជ្យ ។

- ទីចាត់ការគយ និងរដ្ឋាករ នឹងធ្វើកំណត់ហេតុលំអិតនៃការត្រួតពិនិត្យដើម្បីបញ្ចូលទៅក្នុងរបាយការណ៍រួមប្រចាំខែ និងរាយការណ៍ ជូនរាជរដ្ឋាភិបាល (សូមមើលសេចក្ដីណែនាំទី ៦)

(៣) ទីចាត់ការគយ និងរដ្ឋាករនឹងទទួលរ៉ាប់រងការចុះបញ្ជីធម្មតា ធ្វើការត្រួតពិនិត្យ និងប្រមូលពន្ធព្រមទាំងធ្វើការត្រួតពិនិត្យទំនិញដែលបានចុះក្នុងប្រតិវេទន៍ ដើម្បីផ្ទៀងផ្ទាត់ជាមួយនឹងបញ្ជីទំនិញហាមឃាត់ និងបញ្ជីដែលបញ្ចូលរួមគ្នានូវទំនិញហាមឃាត់ ។

(៤) ទីចាត់ការគយ និងរដ្ឋាករ និងកាំកុងត្រូល ត្រូវចាត់តាំងមន្ត្រីពីស្ថាប័នរបស់ខ្លួនមកធ្វើការពិនិត្យឯកសាររួមគ្នា ដើម្បីកំណត់រកទំនិញដែលមានហានិភ័យខ្ពស់ ដែលនឹងចូលទៅក្នុងប្រភេទណាមួយដូចខាងក្រោមៈ

ក. ទំនិញដែលត្រូវបានកំណត់ថាមានហានិភ័យខ្ពស់តាមរយៈការវាយតម្លៃរបស់ស្ថាប័ន

ខ. ទំនិញជាក់លាក់ ដែលត្រូវបានវាយតម្លៃថាមានហានិភ័យខ្ពស់ដោយស្ថាប័ននីមួយៗ

(៥) ការមិនត្រួតពិនិត្យរូបវ័ន្តណាមួយនឹងត្រូវបានធ្វើឡើង លុះត្រាតែឯកសារបែបបទត្រូវបានវាយតម្លៃរួមគ្នារវាងគយ និងកាំកុងត្រូល។ ស្ថាប័ននីមួយៗត្រូវតែយល់ព្រម និងចុះហត្ថលេខាលើសេចក្ដីសម្រេចបញ្ចេញទំនិញដោយគ្មានការត្រួតពិនិត្យរូបវ័ន្ត។

(៦) ប្រសិនបើពាណិជ្ជករស្នើសុំឱ្យមានការត្រួតពិនិត្យនៅក្រៅទីស្នាក់ការត្រួតពិនិត្យ, ទីចាត់ការគយ និងរដ្ឋាករ នឹងសម្របសម្រួលការត្រួតពិនិត្យ, ដែលជាកម្មវត្ថុនៃការវាយតម្លៃហានិភ័យ ដែលរួមមានហានិភ័យក្នុងការផ្លាស់ទីទំនិញចេញពីទីស្នាក់ការត្រួតពិនិត្យ និងអាស្រ័យតាមលទ្ធភាពរបស់មន្ត្រីតាមស្ថាប័ន ។

(៧) ត្រូវមានការពិចារណាដើម្បីបង្កើតនិតិវិធីប្រតិបត្តិការតាមស្តង់ដារ (SOPs) លម្អិតចំពោះរាល់សកម្មភាពទាំងឡាយណាដែលបានអនុវត្តនៅទីស្នាក់ការត្រួតពិនិត្យមាត់ច្រកអន្តរជាតិ ឬមជ្ឈមណ្ឌលដំណើរការត្រួតពិនិត្យ ។

## សេចក្ដីណែនាំទី ៥:

កិច្ចព្រមព្រៀងអន្តរស្ថាប័នត្រូវបានបង្កើតដើម្បីរៀបចំការសម្របសម្រួលការងាររវាងស្ថាប័នគោលនយោបាយ និងស្ថាប័នប្រតិបត្តិ ។ ឯកសារនេះរៀបរាប់ពីគោលបំណងគន្លឹះរបស់ក្រសួង និងស្ថាប័ននីមួយៗ និងកំណត់សេវាកម្មដែលតំរូវឱ្យមាននៅមាត់ច្រកអន្តរជាតិ និងសេវាកម្មដែលនឹងផ្ដល់ដោយស្ថាប័នត្រួតពិនិត្យតាមព្រំដែន

(១) ស្ថាប័ននីមួយៗ បានកំណត់គោលបំណងគន្លឹះរបស់ខ្លួន ក្នុងផែនការការគ្រប់គ្រងហានិភ័យជាយុទ្ធសាស្ត្រ ។ គោលបំណងទាំងនេះត្រូវបញ្ចូលក្នុងកិច្ចព្រមព្រៀងអន្តរស្ថាប័ន ។

(២) កិច្ចព្រមព្រៀងអន្តរស្ថាប័ននីមួយៗ នឹងចាត់តាំងអ្នកផ្តល់សេវាកម្ម និងអ្នកទទួលសេវាកម្ម ។

(៣) កិច្ចព្រមព្រៀងបញ្ជាក់ពីសេវាកម្មដែលនឹងត្រូវផ្តល់ជូននៅទីស្នាក់ការត្រួតពិនិត្យមាត់ច្រកអន្តរជាតិ ដោយស្ថាប័នត្រួតពិនិត្យតាមព្រំដែន និងសេវាកម្មដែលក្រសួងគោលនយោបាយ និងក្រសួងជំនាញរំពឹងចង់បាន ។

(៤) កិច្ចព្រមព្រៀងនេះគប្បីចុះហត្ថលេខាដោយមន្ត្រីជាន់ខ្ពស់បំផុត ឬតំណាង ។

(៥) ក្នុងរយៈពេល ៦ ខែដំបូងនៃប្រតិបត្តិការ កិច្ចព្រមព្រៀង គប្បីត្រូវបានពិនិត្យឡើងវិញឱ្យបានទៀងទាត់ដោយក្រុមសម្របសម្រួលអន្តរស្ថាប័នកំរិតខ្ពស់ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការអនុវត្តន៍ ដែលទាក់ទងទៅនឹងកំរិតនៃសេវាកម្មដែលបានផ្តល់ ។

**សេចក្តីណែនាំទី ៥:**

ក្រសួង និងស្ថាប័ននីមួយៗដែលទទួលខុសត្រូវផ្នែកគោលនយោបាយចំពោះទំនិញហាមឃាត់ និងមានកំរិតកំណត់ ត្រូវបង្កើតបញ្ជីមេមួយដើម្បីដាក់ជូនទីចាត់ការគយ និងរដ្ឋាករ ។ បញ្ជីនេះនឹងបញ្ជាក់ពីសកម្មភាពដែលនឹងត្រូវប្រកាន់យកដោយស្ថាប័នត្រួតពិនិត្យនៅតាមព្រំដែនពេលមានទំនិញនាំចូល ឬនាំចេញ។

ទីចាត់ការគយ និងរដ្ឋាករ នឹងធ្វើចំណាត់ថ្នាក់ទំនិញអនុលោមទៅតាមប្រព័ន្ធស៊ីចង្វាក់ដោយផ្អែកតាមតារាងពន្ធគយកម្ពុជាជាធរមាន ។

បញ្ជីមេនៃទំនិញធ្វើចំណាត់ថ្នាក់ត្រូវផ្តល់ជូនទៅគ្រប់មាត់ច្រកត្រួតពិនិត្យអន្តរជាតិ និងបញ្ចូលទៅក្នុងម៉ូឌុលការគ្រប់គ្រងហានិភ័យនៃស្វ័យប្រវត្តិកម្មកិច្ចការគយ ( ASYCUDA) ។

ស្ថាប័នគោលនយោបាយត្រូវឃ្លាំមើលបញ្ជីមេនេះជាបន្តបន្ទាប់ ហើយបើយល់ថាចាំបាច់ត្រូវទាក់ទងទៅទីចាត់ការគយ និងរដ្ឋាករដើម្បីបន្ថែម ឬលុបចោលមុខទំនិញនៅក្នុងបញ្ជីនេះ ។

(១) អ្នកជំនាញការខាងចំណាត់ថ្នាក់ទំនិញរបស់ទីចាត់ការគយ និងរដ្ឋាករ ត្រូវធ្វើចំណាត់ថ្នាក់លើគ្រប់ទំនិញហាមឃាត់ និងទំនិញជាប់កំរិតកំណត់ ដោយអនុលោមតាមប្រព័ន្ធស៊ីចង្វាក់នៃតារាងពន្ធគយកម្ពុជាជាធរមាន ។

(២) ព័ត៌មានដែលបានមកពីគ្រប់ស្ថាប័ននឹងត្រូវប្រមូលបញ្ចូលគ្នាដោយទីចាត់ការគយ និងរដ្ឋាករ រួច បញ្ជូនទៅគ្រប់ទីស្នាក់ការត្រួតពិនិត្យនៃមាត់ច្រកអន្តរជាតិ និងមជ្ឈមណ្ឌលដំណើរការត្រួតពិនិត្យ ។

(៣) ច្បាប់ចម្លងមួយច្បាប់នៃព័ត៌មានដែលបានរួមបញ្ចូលគ្នា ត្រូវជូនទៅគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ។ ព័ត៌មាននេះត្រូវបើកចំហរជាសាធារណៈដោយចុះផ្សាយនៅក្នុងគេហទំព័ររបស់រាជរដ្ឋាភិបាល ឬបោះពុម្ព ។

(៤)ស្ថាប័ននីមួយៗត្រូវផ្តល់ការណែនាំជាក់លាក់ពីសកម្មភាពដែលតម្រូវចំពោះទំនិញ ដែលមានក្នុងបញ្ជី ហើយត្រូវបានជួបប្រទះនៅមាត់ច្រកអន្តរជាតិ។

(៥) ពេលដែល "ស្ថាប័នឯកទេសមួយ" (ឧទាហរណ៍, ពេទ្យសត្វ, វេជ្ជបណ្ឌិត, វិស្វករអគ្គិសនី) ត្រូវ តម្រូវឱ្យធ្វើកោសល្យវិច័យជាក់លាក់មួយ ហើយជំនាញនេះមិនមាននៅទីចាត់ការគយ និងរដ្ឋាករ ស្ថាប័នជំនាញ ត្រូវផ្តល់អ្នកឯកទេសតាមសំណូមពរ ។

(៦) ទីចាត់ការគយ និងរដ្ឋាករគឺជាចំណុចទំនាក់ទំនងតែមួយគត់ សំរាប់គ្រប់ស្ថាប័ន ដែលធ្វើទំនាក់ទំនង ព័ត៌មានពាក់ព័ន្ធនឹងទំនិញដែលមានហានិភ័យខ្ពស់ រួមមានការផ្តល់ជាលេខទូរសារ ទូរស័ព្ទ ឬលេខទូរស័ព្ទពិសេស ដែលអាចទាក់ទងបានគ្រប់ពេលវេលា ដើម្បីស្នើសុំធ្វើសកម្មភាពអ្វីមួយនៅមាត់ច្រកអន្តរជាតិ ។ ទីចាត់ការគយ និងរដ្ឋាករនៅទីក្រុងភ្នំពេញនឹងរួមបញ្ចូលព័ត៌មានទំនាក់ទំនងលំអិត និងចែកជូនទៅគ្រប់មន្ត្រីជាន់ខ្ពស់របស់ទីចាត់ ការគយ និងរដ្ឋាករ និងកាំកុងត្រូលដែលនៅតាមទីស្នាក់ការត្រួតពិនិត្យនៅតាមមាត់ច្រកអន្តរជាតិ និងមជ្ឈមណ្ឌល ដំណើរការត្រួតពិនិត្យ ។ ដូចគ្នានេះដែរ ស្ថាប័នផ្សេងៗដែលសុំឱ្យគយធ្វើកិច្ចការជំនួសខ្លួនក៏ត្រូវផ្តល់អាស័យដ្ឋាន ទំនាក់ទំនងលំអិតទៅទីចាត់ការគយ និងរដ្ឋាករដើម្បីឱ្យមានការងាយស្រួលក្នុងការទាក់ទងគ្នា។

**សេចក្តីណែនាំទី ៦ :**

ទីចាត់ការគយ និងរដ្ឋាករ និងកាំកុងត្រូលត្រូវប្រមូលព័ត៌មានរួមគ្នាពីចំនួនប្រតិវេទន៍ដែលបានដាក់ និងបានអនុវត្ត ការត្រួតពិនិត្យរូបវ័ន្តជាយថាហេតុ ។ ព័ត៌មាននឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ និងរៀបចំជារបាយការណ៍ជូន នាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីដែលមានតំណាងនៅក្នុងក្រុមសម្របសម្រួលអន្តរស្ថាប័នរៀងរាល់ខែ ។ របាយការណ៍ ត្រូវរៀបរាប់លំអិតពីការរីកចំរើន ដោយប្រៀបធៀបជាមួយគោលដៅកំណត់ពាក់ព័ន្ធនឹងការកាត់បន្ថយការត្រួត ពិនិត្យរូបវ័ន្តរបស់រាជរដ្ឋាភិបាល ។

(១) ទីចាត់ការគយ និងរដ្ឋាករ និងកាំកុងត្រូល នឹងបង្កើតប្រព័ន្ធរាយការណ៍ជាតិរួមគ្នាមួយសំរាប់គ្រប់គ្រងទិន្នន័យនាំចេញ និងនាំចូល ។ ព័ត៌មានដែលនឹងត្រូវប្រមូលត្រូវគិតបញ្ចូលដូចតទៅ:

i. ចំនួនប្រតិវេទន៍ដែលបានដាក់ ( រួមទាំងទំនិញដែលឆ្លង PSI )

ii. ចំនួននៃប្រតិវេទន៍ដែលបានជ្រើសរើសសំរាប់ធ្វើការត្រួតពិនិត្យរូបវ័ន្ត( រួមទាំងទំនិញដែលឆ្លងPSI) ។

(២) ទីចាត់ការគយ និងរដ្ឋាករ និងកាំកុងត្រូល ត្រូវប្រើព័ត៌មានខាងលើ ដើម្បីធ្វើរបាយការណ៍ប្រចាំខែដាក់ជូននាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីដែលមានតំណាងក្នុងក្រុមសម្របសម្រួលអន្តរស្ថាប័ន ។

(៣) របាយការណ៍ទីមួយត្រូវដើរតួជាមូលដ្ឋានមួយសំរាប់ការបង្កើតចំនួននៃការត្រួតពិនិត្យរូបវ័ន្តដែលកំពុងអនុវត្តនៅមាត់ច្រកអន្តរជាតិដោយគ្រប់ស្ថាប័ន ។ របាយការណ៍ជាយថាហេតុនានានឹងបង្ហាញពីលទ្ធផលរបស់ស្ថាប័នទាំងឡាយឆ្លើយតបទៅនឹងគោលដៅនៃការត្រួតពិនិត្យរបស់រាជរដ្ឋាភិបាល ។

## <u>កំណត់សម្គាល់ទី ១</u> [៦]

*ស្តង់ដារប្រទេសអូស្ត្រាលី/ ណូវែលហ្សឺឡង់* ផ្តល់នូវការណែនាំជាមូលដ្ឋានមួយសំរាប់ការគ្រប់គ្រងហានិភ័យ ។ ស្តង់ដារនេះ អាចត្រូវអនុវត្តចំពោះសកម្មភាព សេចក្តីសំរេច ឬ ប្រតិបត្តិការជាច្រើន ក្នុងវិស័យសាធារណៈ ឯកជន ឬ សហគ្រាស ក្រុមមនុស្ស ឬបុគ្គលក្នុងសហគមន៍។ ក្នុងបរិបថ នៃប្រទេសកម្ពុជា ស្ថាប័នដូចជា កាំកុងត្រូល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និង ក្រសួងសុខាភិបាល អាចអនុវត្តស្តង់ដារនេះ និង អាចបំពេញបាននូវតំរូវការទាំងអស់ របស់រាជរដ្ឋាភិបាលកម្ពុជា ។

ស្តង់ដារនេះ បញ្ជាក់អំពីចំណុចសំខាន់ នៃដំណើរការគ្រប់គ្រងហានិភ័យ ក៏ប៉ុន្តែ វាមិនមែនមានគោលបំណង ដើម្បីពង្រឹងដល់ការឯកភាព នៃប្រព័ន្ធគ្រប់គ្រងហានិភ័យឡើយ ។ វាមានលក្ខណៈជាមូលដ្ឋាន និង ឯករាជ្យ ពីវិស័យឧស្សាហកម្ម ឬសេដ្ឋកិច្ចជាពិសេសណាមួយ ។ ការរៀបចំ និង ការអនុវត្តន៏ប្រព័ន្ធគ្រប់គ្រងហានិភ័យ នឹងទទួលឥទ្ធិពលពីសេចក្តីត្រូវការនានារបស់ស្ថាប័ន គោលបំណងជាពិសេស ផលិតផល និង សេវាកម្ម របស់ស្ថាប័ន ហើយនិងដំណើរការ និងការអនុវត្តន៏ ដែលត្រូវបានប្រើប្រាស់ ។

ស្តង់ដារនេះ គួរត្រូវអនុវត្តនៅគ្រប់ដំណាក់កាល នៅក្នុងដំណើរការពីដើមដល់ចប់ នៃសកម្មភាព ភារកិច្ច គំរោង ផលិតផល ឬ ទ្រព្យសកម្មណាមួយ ។ ជាទូទៅ ផលប្រយោជន៏ជាអតិបរមា អាចទទួលបានដោយការអនុវត្តន៏ ដំណើរការគ្រប់គ្រងហានិភ័យ ពីការចាប់ផ្តើមដំបូង ។ ជាញឹកញាប់ ការសិក្សាដាច់ដោយឡែកពីគ្នាមួយចំនួន ត្រូវបានធ្វើឡើងតាមពេលវេលាខុសគ្នា និងចេញពីទស្សនៈយុទ្ធសាស្រ្ត និងប្រតិបត្តិការ ។ ដំណើរការដែលលើក ឡើងនៅក្នុងនេះ អនុវត្តចំពោះការគ្រប់គ្រងទាំងលើសមិទ្ធិផលជាសក្តានុពល និងការខាតបង់ជាសក្តានុពល ។

## <u>ចំណុចសំខាន់ៗ</u>

ចំណុចសំខាន់ៗ នៃដំណើរការគ្រប់គ្រងហានិភ័យ ដូចបានបង្ហាញខាងលើ រួមមានៈ

(ក) ទំនាក់ទំនង និង ពិគ្រោះយោបល់ - ទំនាក់ទំនង និង ពិគ្រោះយោបល់ជាមួយអ្នករួមចំណែកខាងក្នុង និង ខាងក្រៅ តាមការសមស្រប តាមដំណាក់ការនិមួយៗ នៃដំណើរការគ្រប់គ្រងហានិភ័យ និង ទាក់ទងទៅនឹង ដំណើរការទាំងស្រុង ។

[៦] *បទដ្ឋានប្រទេសអូស្ត្រាលី/ ណូវែលហ្សឺឡង់ (AS/NZS 4360:2004)*

(ខ) កសាងបរិការ - កសាងបរិការខាងក្នុង ខាងក្រៅ និងការគ្រប់គ្រងហានិភ័យដែលផ្នែកឯទៀតនៃដំណើរការត្រូវធ្វើឡើង ។ លក្ខណៈវិនិច្ឆ័យដែលហានិភ័យនឹងត្រូវវាយតំលៃប្រៀបធៀបនោះគួរត្រូវបង្កើតឡើង ហើយគួរត្រូវកំណត់អំពីរចនាសម្ព័ន្ធនៃការវិភាគ ។

(គ) កំណត់ហានិភ័យ- កំណត់អំពីទីកន្លែង ពេលវេលា មូលហេតុ និងរបៀប ដែលព្រឹត្តការណ៍នានាអាចនឹងរារាំង បន្ថយកំរិត បន្ទាយពេល ឬ ពង្រឹងដល់ការសំរេចបាននូវគោលបំណង ។

(ឃ) វិភាគហានិភ័យ - កំណត់ និងវាយតំលៃលើការគ្រប់គ្រងបច្ចុប្បន្ន ។ កំណត់អំពីផលវិបាក និងលទ្ធភាព និងកំរិតហានិភ័យ ។ ការវិភាគនេះ គួរតែពិចារណាអំពីបណ្តាផលវិបាកជាសក្តានុពល និងថាតើផលវិបាកទាំងនេះអាចនឹងកើតឡើងដោយរបៀបណា ។

(ង) វាយតំលៃហានិភ័យ - ប្រៀបធៀបកំរិតនៃហានិភ័យដែលត្រូវបានប៉ាន់ស្មាន នឹងលក្ខណៈវិនិច្ឆ័យដែលត្រូវបានកំណត់ជាមុន និងពិចារណាអំពីតុល្យភាពរវាងផលប្រយោជន៍ជាសក្តានុពល និង លទ្ធផលមិនល្អ ។ ប្រការនេះជួយដល់ការធ្វើសេចក្តីសំរេច អំពីទំហំ និងលក្ខណៈ នៃចំណាត់ការជាចាំបាច់ និង អំពីអាទិភាព ។

(ច) ចាត់ការលើហានិភ័យ - កសាង និងអនុវត្តយុទ្ធសាស្ត្រនៃប្រសិទ្ធភាពតំលៃ និង ផែនការសកម្មភាព ដើម្បីបង្កើនផលប្រយោជន៍ជាសក្តានុពល និង កាត់បន្ថយការចំណាយជាសក្តានុពល ។

(ឆ) តាមដាន និង ពិនិត្យឡើងវិញ - ចាំបាច់ត្រូវពិនិត្យតាមដានប្រសិទ្ធិភាពក្នុងរាល់ជំហានទាំងអស់នៃដំណើរការគ្រប់គ្រងហានិភ័យ ។ ប្រការនេះសំខាន់ចំពោះការធ្វើឱ្យប្រសើរឡើងជាលំដាប់ ។ ហានិភ័យ និងប្រសិទ្ធិភាព នៃវិធានការធ្វើចំណាត់ការ ចាំបាច់ត្រូវពិនិត្យដានដើម្បីធានាថា កាលៈទេសៈប្រែប្រួល មិនធ្វើឱ្យផ្លាស់ប្តូរដល់ អាទិភាពឡើយ ។

ការគ្រប់គ្រងហានិភ័យអាចត្រូវអនុវត្ត នៅតាមលំដាប់ថ្នាក់ជាច្រើន នៅក្នុងស្ថាប័នមួយ ។ វាអាចត្រូវអនុវត្ត នៅលំដាប់យុទ្ធសាស្ត្រ និង លំដាប់យុទ្ធវិធី និងប្រតិបត្តិការ ។ វាក៏អាចត្រូវអនុវត្តផងដែរ ចំពោះគំរោងកម្មវិធីជាពិសេសដោយឡែក ដើម្បីជួយដល់ការធ្វើសេចក្តីសំរេចច្បាស់លាស់ ឬ ដើម្បីគ្រប់គ្រង ផ្នែកដែលត្រូវបានទទួលស្គាល់ថាមានហានិភ័យជាពិសេសនោះ ។

ចំពោះដំណាក់កាលនិមួយៗនៃដំណើរការ កំណត់ហេតុគួរត្រូវរក្សាទុក ដើម្បីឱ្យសេចក្តីសំរេចអាចយល់បាន ដែលជាផ្នែកមួយ នៃវិធីធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់ ។

# ដំណើរការគ្រប់គ្រងហានិភ័យ-បរិបថសង្ខេប



## ដំណើរការគ្រប់គ្រងហានិភ័យ — បរិបទពិស្តារ



## កំណត់សម្គាល់ទី ២[៧]

### ដំណើរការគ្រប់គ្រងហានិភ័យ

ដំណើរការគ្រប់គ្រងហានិភ័យ រួមមានការកសាងបរិការគ្រប់គ្រងហានិភ័យ ការកំណត់អំពីហានិភ័យ ការវិភាគអំពីហានិភ័យ ការដោះស្រាយហានិភ័យ និងការតាមដានត្រួតពិនិត្យឡើងវិញលើដំណើរការ តាមរយៈការវាស់ស្ទង់អំពីការគោរពតាម ។




[៧] WCO បានពិនិត្យសំរួលឡើងវិញអនុសញ្ញា Kyoto , General Annex Guiliness, Chapter 6 – Customs Control

**(ក) កសាងបរិការ**

ជំហាននេះ បង្កើតនូវបរិការជាយុទ្ធសាស្ត្រ និងជាលក្ខណៈស្ថាប័ន ដែលនៅក្នុងនោះ ការគ្រប់គ្រងហានិភ័យនឹងប្រព្រឹត្តទៅបាន ។ ត្រូវតែកំណត់បណ្តាផ្នែកដែលមានហានិភ័យ ហើយត្រូវតែវាយតំលៃ និងបង្កើតឡើងនូវលក្ខណៈវិនិច្ឆ័យចំពោះផ្នែកដែលមានហានិភ័យ ហើយក៏ត្រូវតែកំណត់អំពីរចនាសម្ព័ន្ធនៃការវិភាគ ។

ការគ្រប់គ្រងហានិភ័យនៅក្នុងផ្នែកគយអាចមានលក្ខណៈជាយុទ្ធសាស្ត្រ ប្រតិបត្តិការ ឬយុទ្ធវិធី ។ គួរតែចាំថាដំណើរការគ្រប់គ្រងហានិភ័យ អាចនឹងអនុវត្ត ចំពោះគ្រប់លំដាប់ថ្នាក់ទាំងអស់នេះ ។

**ការគ្រប់គ្រងហានិភ័យជាយុទ្ធសាស្ត្រ** - តាមរយៈការសិក្សាអំពីព័ត៌មានយ៉ាងទូលំទូលាយនោះ រដ្ឋបាលគយ អាចកំណត់អំពីបណ្តាផ្នែកនៃហានិភ័យ ដកយកចេញនូវចំណុចណាដែលមានសារសំខាន់តិចតួច និងធ្វើអន្តរាគមន៍តែក្នុងករណីដែល ការវិនិច្ឆ័យមានបទពិសោធន៍ និង ជាក់ស្តែងបានកំណត់ជាចាំបាច់ ។

បណ្តាផ្នែកដែលមានហានិភ័យនៅក្នុងបរិការផ្នែកគយ អាចរួមមានទាំងបញ្ហាសង្គម (លើកលែងតែបញ្ហាគ្រឿងញៀន រូបអាសអាភាស ។ល។) ការហាមឃាត់ និងការដាក់កំហិតលើការនាំចេញ-នាំចូល (ឧ. អនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើពូជរុក្ខជាតិ និងសត្វដែលអាចនឹងផុតពូជ (CITES)) បញ្ហាសុខាភិបាល បរិស្ថានវិធានការ គោលនយោបាយ ផ្នែកពាណិជ្ជកម្ម (ឧ. សិទ្ធិកម្មសិទ្ធិបញ្ញា (IPR) ប្រព័ន្ធអនុគ្រោះ (GSP)) កូតា (quotas) និង បញ្ហា ពន្ធគយ និង អាករ ។

**ការគ្រប់គ្រងហានិភ័យផ្នែកប្រតិបត្តិការ** - គឺជាការកំណត់កំរិតនៃការគ្រប់គ្រងដែលចាំបាច់ដើម្បីដោះស្រាយឱ្យមានប្រសិទ្ធភាពចំពោះហានិភ័យដែលបានវាយតំលៃ ។ ឧទាហរណ៍នេះ គឺកំណត់អំពីការគ្រប់គ្រងលើសវនកម្មដែលអនុវត្តចំពោះអ្នកនាំចូល ឬ ថាតើត្រូវបែងចែកមន្ត្រី និងឧបករណ៍ដែលមានតិចតួចដោយវិធីណាឱ្យមានប្រសិទ្ធិភាព ។ ដោយការប្រើប្រាស់វិធីសាស្ត្រនេះ ផ្នែកគយ ប្រែក្លាយពី " អ្នកចាំយាមច្រកទ្វារ " ដែលត្រួតពិនិត្យរាល់សកម្មភាព ទៅជាការត្រួតពិនិត្យចំពោះតែសកម្មភាពណាត្រូវបានជ្រើសរើស ដែលបង្ហាញពីហានិភ័យដ៏ធំបំផុត ។

**ការគ្រប់គ្រងហានិភ័យផ្នែកយុទ្ធវិធី** - ត្រូវបានប្រើប្រាស់ដោយមន្ត្រីទាំងឡាយ នៅអង្គភាពរបស់ខ្លួន ដើម្បីចាត់ការនឹងស្ថានភាពបន្ទាន់ ។ ដោយការប្រើប្រាស់នីតិវិធី ដែលបានកំណត់រួច ជាមួយនិងបញ្ហា បទពិសោធន៍ និងជំនាញនោះ មន្ត្រីទាំងឡាយ សំរេចថាតើសកម្មភាពណា គំរូវអោយមានការត្រួតពិនិត្យខ្លាំង ។

**(ខ) កំណត់ហានិភ័យ**

កំណត់អំពីអ្វី ហេតុអ្វី និងវិធីណា ដែលហានិភ័យអាចលេចឡើង ជាមូលដ្ឋានសំរាប់ការវិភាគជាបន្តទៀត ។ ជំហាននេះតំរូវឱ្យមានការអធិប្បាយស៊ីជំរៅ អំពីដំណើរការត្រួតពិនិត្យបច្ចុប្បន្ន ដើម្បីរួមបញ្ចូល :

- អ្នកចូលរួម / អតិថិជន / ភាគីពាក់ព័ន្ធ
- ចំណុចខ្លាំង និងចំណុចខ្សោយ
- ទីណា ពេលណា វិធីណា ដែលហានិភ័យទំនងជានឹងធ្វើឱ្យកើតឡើង និងដោយអ្នកណា
- អ្វីទៅជាការគំរាមកំហែង និងផលប៉ះពាល់របស់វា ក្នុងករណីត្រូវចៀសវាង
- ហេតុអ្វីមានឱកាសសំរាប់ការចៀសវាង

**(គ) វិភាគអំពីហានិភ័យ**

កំណត់អំពីការត្រួតពិនិត្យ និងវិភាគអំពីហានិភ័យ ទាក់ទងនឹងលទ្ធភាពដែលអាចកើតឡើង និង ផលវិបាក ។ ការវិភាគគួរតែពិចារណាអំពី :

- តើព្រឹត្តការណ៍ នឹងអាចកើតឡើងដោយរបៀបណា
- តើផលវិបាកជាសក្តានុពល និង ទំហំរបស់វា មានអ្វីខ្លះ ។

បូកបញ្ចូលចំណុចសំខាន់ទាំងនេះ ដើម្បីបង្កើតជាកំរិតប៉ាន់ប្រមាណអំពីហានិភ័យ ។ ផ្នែកគយគួរត្រូវអនុវត្តការវាស់ស្ទង់អំពីអនុលោមភាពសម្រាប់ទ្រទ្រង់ដល់ភារកិច្ចនេះ ។

ប្រសិនបើកំរិតប៉ាន់ប្រមាណ មានកំរិតទាបនោះ ហានិភ័យអាចនឹងធ្លាក់ចូលក្នុងប្រភេទអាចទទួលយកបាន ហើយប្រហែលជាមិនត្រូវការវិធានការឡើយ ។

**(ឃ) វាយតំលៃ និង កំណត់អាទិភាពលើហានិភ័យ**

ធ្វើការប្រៀបធៀបកំរិតប៉ាន់ប្រមាណអំពីហានិភ័យ ទៅនឹងលក្ខណៈវិនិច្ឆ័យដែលត្រូវបានកំណត់ជាមុន ។ ធ្វើចំណាត់ថ្នាក់លើហានិភ័យ ដើម្បីកំណត់ពីអាទិភាពគ្រប់គ្រង ។ មានប្រព័ន្ធធ្វើចំណាត់ថ្នាក់ជាច្រើនប្រភេទ ។ ការវាយតំលៃជាកំរិត **ខ្ពស់ មធ្យម** និង **ទាប** គឺមានជាទូទៅ ។ នៅក្នុងបរិយាកាសស្មុកស្មាញ អាចនឹងត្រូវការប្រព័ន្ធដែលមានលក្ខណៈលំអិតមួយ ដូចជា ការចាត់ថ្នាក់ ពី ១ ដល់ ១០០ ។ ប្រព័ន្ធនេះ ក៏ត្រូវការសំរេចអំពី ម៉ាទ្រីសកំរិត **ខ្ពស់**

និង **ទាប** ផងដែរ ក៏ប៉ុន្តែ ត្រូវឱ្យមានភាពកាន់តែច្បាស់លាស់ ។ ត្រូវតាមដាន ហានិភ័យជាបន្តបន្ទាប់ ដើម្បីពិនិត្យការប្រែប្រួលអំពី លក្ខណៈ កំរិត ឬ ផលប៉ះពាល់ ។

**(ង) ដោះស្រាយបញ្ហាហានិភ័យ**

ទទួលយក និងតាមដានហានិភ័យដែលមានអាទិភាពកំរិតទាប (low-priority risks) ។ ចំពោះហានិភ័យឯទៀតត្រូវកសាង និងអនុវត្តផែនការគ្រប់គ្រងជាពិសេសដោយឡែក ដែលរួមមានការពិចារណាអំពីប្រភពធនធាន (មនុស្ស ថវិកា និង បច្ចេកទេស) ។

**(ច) តាមដាន និង ពិនិត្យឡើងវិញ - ការវាស់ស្ទង់អំពីការគោរពតាម**

តាមដាន និងពិនិត្យឡើងវិញអំពីការអនុវត្តន៏ និងប្រសិទ្ធិភាព នៃប្រព័ន្ធគ្រប់គ្រងហានិភ័យ និងការប្រែប្រួលដែលអាចនឹងប៉ះពាល់លើប្រព័ន្ធនោះ ។

ដើម្បីឱ្យនៅតែមានប្រសិទ្ធិភាព ប្រព័ន្ធគ្រប់គ្រងហានិភ័យណាក៏ដោយ ត្រូវតែសាកល្បងអំពីការវាយតំលៃលើហានិភ័យដែលត្រូវបានកំណត់ពីមុន និងត្រូវតែមានភាពទន់ភ្លន់បត់បែនគ្រប់គ្រាន់ ដើម្បីឆ្លុះបញ្ចាំងអំពីហានិភ័យដែលត្រូវបានកំណត់ថ្មីៗ ។ ការវាយតំលៃប្រសិទ្ធិភាពនៃការគ្រប់គ្រងហានិភ័យគួរត្រូវអនុវត្តជាទៀងទាត់នៅគ្រប់ដំណាក់កាលទាំងអស់ ។ អត្រាមានជោគជ័យ គឺជាលក្ខណៈវិនិច្ឆ័យសំខាន់មួយសំរាប់ការវាតំលៃប្រសិទ្ធិភាពនៃប្រវត្តិហានិភ័យ ។ ការវាយតំលៃ និងការពិនិត្យឡើងវិញ ត្រូវអនុវត្តដោយផ្នែកគយ ជាទៀតទាត់តាមរយៈដំណើរការនៃការវាស់ស្ទង់ការគោរពតាម ។ វាក៏អាចត្រូវអនុវត្ត តាមរយៈសវនកម្ម ខាងក្រៅរបស់រដ្ឋាភិបាលដោយអាជ្ញាធរសវនកម្មស្រមច្បាប់ ដូចជាអ្នកជំរះបញ្ជី ឬ អគ្គសវនករ ។ ទោះបីជា ទំហំ និងវិធីសាស្ត្រនៃការពិនិត្យឡើងវិញទាំងនេះ ខុសប្លែកពីគ្នាក៏ដោយ ក៏គោលបំណងរបស់វា គឺដើម្បីកំណត់ចំណុចខ្សោយនៅក្នុងកម្មវិធីត្រួតពិនិត្យ និងដើម្បីធ្វើអនុសាសន៏ចំពោះការកែលំអ ។

សូចនាករហានិភ័យ នឹងលេចឡើងគ្រប់ពេលវេលា ។ ផ្នែកគយ គួរតែធ្វើបច្ចុប្បន្នកម្មនូវសូចនាករទាំងនោះដោយការពិនិត្យមើលពីប្រភពព័តិមានផ្សេងៗ ដូចជា ព្រឹត្តប័ត្រ WCO Enforcement Bulletin មណ្ឌលទិន្នន័យអន្តរជាតិស្តីពីព័តិមានអំពីឈ្មួញ (ឧ. Dun & Bradstreet, Loloyd's Shipping register) ។ល។

ប្រវត្តិហានិភ័យគួរតែពិនិត្យឡើងវិញ នៅចន្លោះពេលជាទៀងទាត់ ដើម្បីធានាថា វាទាន់សាភាពការណ៍ជានិច្ច និងចៀសវាងប្រព័ន្ធព័ត៌មានដែលមិនពាក់ព័ន្ធតទៅទៀត ។ វាក៏សំខាន់ផងដែរ ដែលត្រូវរក្សាឱ្យមានការភ្ញាក់ផ្អើលដោយការត្រួតពិនិត្យមិនតាមលំដាប់លំដោយ ព្រោះថាក្រុមហ៊ុនដែលមានទំនាក់ទំនងជាប់លាប់ជាមួយផ្នែកគយនឹងស្វែងយល់អំពីវិធីកត់ត្រាប្រវត្តិ ឬ ជូនកាលអំពីប្រវត្តិនោះតែម្តង ។ ការត្រួតពិនិត្យមិនតាមលំដាប់លំដោយទាំងនេះ អាចផ្តល់នូវមធ្យោបាយមិនអស់សោហ៊ុយច្រើន ក្នុងការកំណត់ហានិភ័យប្រភេទឯទៀត និងក្នុងការប៉ាន់ប្រមាណអំពីសារសំខាន់របស់វា ឬក៏ការប្រែប្រួលនៃលក្ខណៈហានិភ័យ ។

ការពិនិត្យឡើងវិញ និងការវាយតំលៃ នៅក្នុងដំណើការគ្រប់គ្រងហានិភ័យ គួរត្រូវបញ្ចូលក្នុងនីតិវិធីនៃការពិនិត្យឡើងវិញជាទៀងទាត់ ដើម្បីវាស់ស្ទង់ និង វាយតំលៃប្រសិទ្ធិភាព នៃកម្មវិធីត្រួតពិនិត្យផ្នែកគយទូទៅ និងគួរតែពិចារណាអំពីការពិនិត្យឃើញ របស់សវនកម្មពីខាងក្រៅរបស់រដ្ឋាភិបាល ។

មន្ត្រីគ្រប់ជាន់ថ្នាក់ គួរតែចូលរួមនៅក្នុងការពិនិត្យឡើងវិញជាប្រចាំនេះ ។ យោបល់កែលំអពីមន្ត្រីនានាគឺមានសារៈសំខាន់ណាស់ ដើម្បីឱ្យការធ្វើឱ្យមានសុពលភាពជានិរន្តអាចនឹងកើតឡើង ហើយការធ្វើបច្ចុប្បន្នកម្មជាចាំបាច់អាចនឹងត្រូវអនុវត្តបាន ។

**(ឌ) ការរៀបចំជាឯកសារ**

គួរតែមានបញ្ជីហានិភ័យមួយ ដែលផ្តល់នូវសនិទានភាព នៅពីក្រោយការជ្រើសរើសហានិភ័យ និងកត់ត្រាអំពីការសន្មត់ ដែលការវាយតំលៃត្រូវបានធ្វើឡើងនោះ ដើម្បីកសាងបាននូវវិធីធ្វើសវនកម្មមួយ ដែលធានាថាព័ត៌មាន សំខាន់ៗមិនបាត់បង់ ។




| | | | |
|---|---|---|---|
| - ចំនួនកូតា | ប្រភេទទំនិញ | វាយនភ័ណ្ឌក្រោមកូតា | វាយនភ័ណ្ឌក្រោមកូតា ឬ |
| - ប្រព័ន្ធអនុគ្រោះ | ប្រទេសដើម | ប្រទេសដើមជាក់លាក់ | ប្រទេសដើមជាក់លាក់ ឬ |
| -អនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើពូជរុក្ខជាតិនិងសត្វដែលអាចនឹងផុតពូជ | ផ្លូវដឹកជញ្ជូន | ផ្លូវដឹកជញ្ជូនដែលមិនធម្មតា | ផ្លូវដឹកជញ្ជូនដែលមិនធម្មតា ឬ |
| - ឈ្មួញ | ម្ចាស់ទំនិញ | ម្ចាស់ទំនិញជាក់លាក់ | ម្ចាស់ទំនិញជាក់លាក់ |
| ។ល។ និង ។ល។ | ។ល។ និង ។ល។ | ។ល។ និង ។ល។ | |

## វិស័យនៃវិធានការណ៍អនុលោមភាព

ការប្រើកម្មវិធីការគ្រប់គ្រងហានិភ័យគយគប្បីកំណត់វិស័យអាទិភាពដើម្បីផ្តោតការយកចិត្តទុកដាក់ទៅលើធនធានរបស់វិស័យនោះ ។ វិធីសាស្ត្រមួយដើម្បីធ្វើការពិចារណាក្នុងករណីប្រទេសមួយចំនួន ឬសហគមន៍សេដ្ឋកិច្ចដែលមានច្រើនរហូតដល់ ១០% នៃឈ្មួញតំណាងឱ្យច្រើនជាង ៨០% នៃការនាំចូល និងនាំចេញ ដោយធ្វើការយកចិត្តទុកដាក់តែលើផ្នែកខាងលើ ៥-១០% នៃឧស្សាហករដែលមានចំនួនច្រើនបំផុត អ្នកនាំចូល អ្នកនាំចេញ និងទំនិញទីចាត់ការគយនិងរដ្ឋាករអាចធានាថាចំនួនទាំងនោះដែលមានផលប៉ះពាល់ខ្លាំងបំផុតដល់សេដ្ឋកិច្ចជាតិអាចនឹងត្រូវបានពិនិត្យឡើងវិញយ៉ាងមានប្រសិទ្ធភាពបំផុត ។

វិស័យទាំងនោះអាចរួមមានៈ

**បញ្ហាឯកសារៈ**

- ការចាត់ថ្នាក់តារាងពន្ធគយយ៉ាងត្រឹមត្រូវដោយពួកឈ្មួញ
- ការវាយតំលៃយ៉ាងត្រឹមត្រូវដោយពួកឈ្មួញ
- ប្រទេសដើម ។

**បញ្ហានីតិវិធី:**

- ការនាំចូល និងនាំចេញ (ចាប់ពីការប្រកាសទំនិញ រហូតដល់ការប្រមូលចំណូល)
- ការត្រិបត្តិការឆ្លងកាត់
- ការទុកដាក់ក្នុងឃ្លាំង តំបន់ពាណិជ្ជកម្មពិសេស កិច្ចដំណើរការ ។

**បញ្ហាចំណូល:**

- ការបង់ចំណូលទាន់ពេល និងត្រឹមត្រូវ
- ទុកដាក់ឱ្យបានត្រឹមត្រូវដើម្បីសុវត្ថិភាព ។

**បញ្ហាដឹកជញ្ជូន:**

- រាយការណ៍ឱ្យបានត្រឹមត្រូវនូវចំនួនទំនិញ
- ពិពណ៌នាឱ្យបានត្រឹមត្រូវអំពីទំនិញលើនិវេទនប័ណ្ណ និង/ឬឯកសារដឹកជញ្ជូន
- ភាពត្រឹមត្រូវនៃចំនួនកុងតឺន័រ និងលេខអត្តសញ្ញាណ
- ការគោរពតាមរបស់អ្នកដឹកជញ្ជូន ។

**បញ្ហាដាក់លាក់:**

- ភាពស្របតាមលេខសម្គាល់តារាងពន្ធគយ
- បញ្ហាសុខភាពសាធារណៈ និងសុវត្ថិភាព
- បញ្ហាកម្មសិទ្ធបញ្ញា និងចតចម្លង
- គោរពតាមកិច្ចព្រមព្រៀងពាណិជ្ជកម្ម
- ដាក់ស្លាកសញ្ញានៃប្រទេសដើមលើទំនិញឱ្យបានត្រឹមត្រូវ
- ទំនិញដែលមានចំណូលខ្ពស់
- ពាណិជ្ជករដែលបានជ្រើសរើស ។

**ដំណើរការវិធានការណ៍**

ទីចាត់ការគយ និងរដ្ឋាករប្រមូលទិន្នន័យពីប្រភពផ្សេងៗ, ទាំងក្នុង និងក្រៅ, និងតាមរយៈឯកសារដោយដៃ និងស្វ័យប្រវត្តិ ។ នៅក្នុងទិន្នន័យនោះ (កំណត់ត្រានាំចេញ និងនាំចូល), ឧបករណ៍ (ការវិភាគស្ថិតិ) និងវិធីសាស្ត្រ (ការវិភាគដោយ ប្រព័ន្ធទៅលើពាណិជ្ជករ ឬទំនិញធំៗ), ទីចាត់ការគយ និងរដ្ឋាករ អាចធ្វើសេចក្តីសម្រេចដែល មានហេតុផល និងដែលអាចរាយការណ៍បានអំពីអត្រាគោរពតាមរបស់ក្រុមហ៊ុនជាច្រើន ។ អត្រាទាំងនេះអាច ត្រូវបានកំណត់សំរាប់មហាជននីមួយៗនៃដំណើរការប្រតិបត្តការ, ឧទាហរណ៍ សំរាប់ការ នាំចូល, នាំចេញ,

និវេទនប័ណ្ណ ទៅដល់ការប្រកាសទំនិញ និងទៅដល់ការប្រមូលពន្ធ និងអាករ។ ប្រព័ន្ធស្វ័យតកម្មដែលទីចាត់ការគយ និងរដ្ឋាករ ប្រើដើម្បីវាយតម្លៃទំនិញដែលមានហានិភ័យខ្ពស់អាចគាំទ្រនូវតម្រូវការពិនិត្យការគោរពតាមឡើងវិញរបស់វិធីសាស្ត្រដែលមានលក្ខណៈវិទ្យាសាស្ត្រ ដើម្បីធ្វើការប្រមូលទិន្នន័យ ធ្វើការវិភាគ និងធ្វើការគ្រោងទុកឱ្យបានសុក្រឹត្យ បើទោះបីជាអត្រាគោរពតាមអាចធ្វើការវាស់វែងបានយ៉ាងមានប្រសិទ្ធភាពដោយមិនចាំបាច់មានស្វ័យប្រវត្តិកម្មក៏ដោយ ។

ទីចាត់ការគយ និងរដ្ឋាករគប្បីកំណត់ក្រុមប្រតិបត្តិការ និងប្រើវិធីសាស្ត្រយកគំរូដែលមានសុពលភាពតាមលក្ខណៈស្ថិតិ. ជ្រើសរើស ប្រតិបត្តិការជាក់លាក់ ឬ ក្រុមហ៊ុនផ្សេងៗពីក្រុមប្រតិបត្តិការនេះដើម្បីពិនិត្យឡើងវិញ ឬធ្វើការបញ្ជាក់ ។ ផ្អែកលើលទ្ធផល. ក្រុមប្រតិបត្តិការនេះអាចកែប្រែបានច្រើនយ៉ាង ។

ទីចាត់ការគយ និងរដ្ឋាករគួរតែកំណត់ផងដែរនូវកំរិតនៃការគោរពតាម ដែលអាចទទួលយកបាន។ ឧទាហរណ៍. អាត្រាគោរពតាម ៩៥% នៃប្រតិបត្តិការ ឬអង្គភាពដែលបានពិនិត្យឡើងវិញក្នុងផ្នែកណាមួយដែលបានផ្តល់ឱ្យអាចជាកំរិតដែលអាចទទួលយកបានសំរាប់កិច្ចការរដ្ឋបាល ។ នេះក៏អាចហៅបានថាកំរិតនៃការអត់ធ្មត់ ។ ដំណើរការប្រតិបត្តិការមួយចំនួនសំរាប់ធ្វើការផ្ទៀងផ្ទាត់នូវអនុលោមភាព មាន:

- អនុលោមភាពនៃប្រតិវេទន៍ទំនិញ
- អនុលោមភាពរបស់ពាណិជ្ជករ
- អនុលោមភាពនៃការឆ្លងកាត់
- អនុលោមភាពនៃតំបន់រួចពន្ធ ឬឃ្លាំងទំនិញ
- អនុលោមភាពនៃឯកសារនិវេទនប័ណ្ណ និងឯកសារដឹកជញ្ជូន
- ការគោរពតាមរបស់អ្នកដឹកជញ្ជូន ។

កត្តាមួយចំនួនខាងក្រោម ដែលគប្បីយកមកពិចារណាក្នុងពេលពិនិត្យការបញ្ជាក់សំរាប់ឧទាហរណ៍មួយដែលបានជ្រើសរើសនៃដំណើរការនេះ ។

អនុលោមភាពនៃប្រតិវេទន៍ទំនិញ

ក) តើមានភស្តុតាងនៃការរៀបចំឯកសារណាដែលគាំទ្រការប្រកាសទំនិញដ៏ត្រឹមត្រូវមួយឬទេ ?

ខ) តើចំនួនទំនិញដែលប្រកាសស៊ីគ្នានឹងទំនិញដែលបានផ្ទុកឬទេ ?

គ) តើប្រទេសដើមដែលបានប្រកាសស៊ីគ្នានឹងប្រទេសដើមដែលមានស្លាកសញ្ញានៅលើទំនិញឬទេ ?

ឃ) តើការពិពណ៌នាទំនិញដែលបានប្រកាសស៊ីគ្នាទៅនឹងទំនិញជាក់ស្តែងឬទេ ?

ដូច្នេះការពិនិត្យឡើងវិញនូវវិធានការណ៍អនុលោមភាពមានការទាក់ទងទៅនឹងកម្មសិទ្ធិបញ្ជាចំពោះទំនិញដែលបានជ្រើសរើស. នៅកំរិតមួយដែលអាចទទួលយកបានគឺ ៩៥%. អាចវិវឌ្ឍន៍ទៅបានដូចខាងក្រោមនេះ:

ក) អនុវត្តការយកគំរូទំនិញដោយចន្លោះៗដែលមានសុពលភាពជាលក្ខណៈស្ថិតិ សំរាប់លេខប្រព័ន្ធស៊ីចង្វាក់ ។
ខ) ប្រសិនបើលទ្ធផលអត្រាគោរពតាមតិចជាង ៩៥% អនុវត្តវិធានការណ៍ផ្សេងមួយទៀតដែលជាលេខប្រព័ន្ធស៊ីចង្វាក់ដដែល ប៉ុន្តែត្រូវបានចាត់ថ្នាក់តាមប្រទេសដើមដែលបានជ្រើសរើស ។
គ) ចំពោះប្រទេសដើមដែលរកឃើញថាមានអត្រាគោរពតាមតិចជាង ៩៥% , អនុវត្តវិធានការណ៍មួយចំពោះគ្រប់អ្នកនាំចូលដែលចំបង ។
ឃ) សំរាប់អ្នកនាំចូលដែលរកឃើញថាមានអត្រាអនុវត្តតាមតិចជាង ៩៥% ទីចាត់ការគយ និងរដ្ឋាករគប្បីព្យាយាម:

- ជម្រាបដល់អ្នកនាំចូល ( អនុលោមភាពដែលបានជម្រាប),
- បង្កើតការស្រង់សាវតា ការកំណត់គោលដៅលើផ្នែកដែលបានកំណត់នៃការមិនមានអនុលោមភាព
- អនុវត្តវិធានការណ៍ជាបន្តបន្ទាប់ដើម្បីធានាថាអ្នកនាំចូលបានកែសំរួលបញ្ហា.
- អនុវត្តការពិនិត្យឡើងវិញ ឬការពិនិត្យទំនិញឱ្យបានច្រើនដង.
- បង្កើតការផាកពិន័យ ឬដាក់ទោស. បើគួរធ្វើ. ក្នុងករណីបន្តការមិនគោរពតាម

## ការប្រើលទ្ធផលវិធានការណ៍អនុលោមភាពនៅក្នុងកម្មវិធីត្រួតពិនិត្យ

ដូចបានបញ្ជាក់ពីដំបូង. វិធានការណ៍អនុលោមភាពគឺជាផ្នែកមួយនៃកម្មវិធីត្រួតពិនិត្យរបស់គយដោយប្រសិទ្ធិភាព ។ ការប្រើនីតិវិធីវាស់ស្ទង់កំរិតអនុលោមភាពដែលមានសុពលភាពជាលក្ខណៈស្ថិតិអាចត្រូវបានប្រើប្រាស់ក្នុងផ្លូវនានាៈ

- កំណត់ការខ្វះចន្លោះណាមួយនៃចំណូល
- ការពារការរាលដាលនៃការក្លែងបន្លំពាណិជ្ជកម្ម
- វាយតម្លៃការអនុវត្តន៍ការងារដោយឧស្សាហកម្មចម្បង
- វាយតម្លៃការអនុវត្តន៍ការងារដោយអ្នកនាំចូល និងអ្នកនាំចេញចម្បង
- បង្កើនអនុលោមភាពក្នុងពាណិជ្ជកម្ម
- ដាក់វិធានការណ៍ពាណិជ្ជកម្មអន្តរជាតិឱ្យបានត្រឹមត្រូវ

លទ្ធផលនៃការវាស់ស្ទង់នេះអាចជួយទៅរកប្រភពត្រឹមត្រូវហើយមានប្រសិទ្ធភាព ។ ក្នុងការកំណត់អត្រានៃអនុលោមភាពសំរាប់អ្នកនាំចូលនីមួយៗ បុគ្គលណាដែលបានរកឃើញថាមានអត្រាអនុលោមភាពខ្ពស់ ទំនិញរបស់គេនឹងអាចត្រូវបានត្រួតពិនិត្យតិចជាង ខណៈពេលដែលបុគ្គលណាមានអត្រាអនុលោមភាពទាបទំនិញរបស់គេនឹងត្រូវបានត្រួតពិនិត្យច្រើនជាង ។

លទ្ធផលនៃការពិនិត្យឡើងវិញនូវអនុលោមភាពរបស់ទំនិញ ពាណិជ្ជករ និងឧស្សាហកម្ម បានផ្តល់ព័ត៌មានដើម្បីធ្វើឱ្យទាន់សម័យនូវលក្ខណៈវិនិច្ឆ័យដែលជ្រើសរើសដែលមានស្រាប់ ដើម្បីប្រើក្នុងការកំណត់គោលដៅប្រតិបត្តិការដែលមានហានិភ័យខ្ពស់ ព្រមទាំងប្រសិទ្ធភាពទូទៅនៃកម្មវិធីគ្រប់គ្រងហានិភ័យរដ្ឋបាល ។ លើសពីនេះទៀតលទ្ធផលនេះនឹងចូលរួមយ៉ាងសំខាន់ឆ្ពោះទៅកាន់និន្នាការដែលបានកំណត់ និងបញ្ហាដែលទាក់ទងទៅនឹងវិស័យឧស្សាហកម្មជាក់លាក់ណាមួយ ។ លទ្ធផលនេះគប្បីផ្តោតលើការវិភាគព័ត៌មានដែលមានជាបន្ទាន់ ដើម្បីជួយដល់មន្ត្រីគយក្នុងសកម្មភាពការងារប្រចាំថ្ងៃ ។